**BMI0132**

## សម្ភាសន៍ជាមួយឈ្មោះ កេត វ៉ាត់ ភេទស្រី អាយុឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម "ប្រជាជនធ្វើការនៅកងចល័ត "
## រស់នៅភូមិស្រះកើត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឆាយ ឈុនលី
## ០១:២០:២៦
## ៣៦ទំព័រ

ឈុនលី : អឺចេះអ៊ំ ខ្ញុំឈ្មោះឈុនលី ធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំចុះមកដើម្បីចង់ដឹងសួរនាំពីប្រវត្តិរបស់អ៊ំដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ហើយពិបាកយ៉ាងម៉េចចឹងទៅណាស ដើម្បីឲ្យយកទៅសរសេរសៀវភៅទស្សនាវដ្ដីទុកឲ្យក្មេងមើល ក្មេងជំនាន់ក្រោយដែលអត់ដឹងអីចឹងឲ្យគាត់មើល ។ ព្រោះអ្នកខ្លះអត់ជឿទេ មានខ្មែរក្រហមចឹងណាស ។ ចឹងអត់អីទេហ្អីអ៊ំ ខ្ញុំសុំសំភាសបាន សំភាសពីសាច់រឿងរបស់អ៊ំបាន? សរសេរអត្ថបទចឹងណាស ដូចនេះគាត់ជាអ្នកសិល្បៈមជ្ឈឹមខ្មែរក្រហម នេះខ្ញុំទៅសំភាសគាត់នៅម៉ាឡៃ ហើយខ្ញុំមកសំភាសអ៊ំរបៀបអីចឹងមកសសេរសាច់រឿងចុះដូចគាត់ចឹង ។

វ៉ាត់ : ណុងឯងកាលសម័យខ្មែរក្រហម ។

ឈុនលី : ចឹងអត់អីទេអ៊ំហ្អី ខ្ញុំអាចសំភាសអ៊ំបាន? ព្រោះខ្ញុំចង់សសេរសាច់រឿងអ៊ំ ហើយក្នុងនោះខ្ញុំសុំថតរូបអ៊ំដែរ ដូចគាត់ចឹងថតរូបហើយសសេរសាច់រឿងដាក់ថាអ៊ំពិបាកម៉េចខ្លះអីចឹងអត់អីទេហ្អីអ៊ំ?

វ៉ាត់ : អត់អីទេ ។

ឈុនលី : ចាស!អីចឹងខ្ញុំសុំចាប់ផ្ដើមតែម្ដង!ដំបូងខ្ញុំចង់ដឹងឈ្មោះអ៊ំម្ដងទៀត?

វ៉ាត់ : កេត វ៉ាត់ ។

ឈុនលី : ចាស អ៊ំឈ្មោះកេត វ៉ាត់ ។ អាយុប៉ុន្មានហើយអ៊ំ?

វ៉ាត់ : ខ្ញុំ៥៧ហើយ ។

ឈុនលី : ៥៧ ភេទស្រី ហើយនៅនេះគេហៅភូមិអីគេ?

វ៉ាត់ : ភូមិប៉ោយក្អៀង ។

ឈុនលី : ភូមិប៉ោយក្អៀង ឃុំព្រះនេត្រព្រះ?


66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

វ៉ាត់ : ឃុំព្រះនេត្រព្រះ ។

ឈុនលី : ស្រុកព្រះនេត្រព្រះដែរ?

វ៉ាត់ : ចាស!

ឈុនលី : ចុះស្រុកកំណើតពីដើមមកអីនៅឯណា?

វ៉ាត់ : ភូមិប៉ោយក្បឿងនេះឯង ។

ឈុនលី : នៅភូមិប៉ោយក្បឿងដែរ?

វ៉ាត់ : ហ្អស!កាលនោះគេជម្លៀសឲ្យទៅនៅស្រេះ ស្រេះយើងស្រេះកើតនេះណាស ។

ឈុនលី : ស្រេះ?

វ៉ាត់ : ចាស ដែលអាពតចូលមកឆ្នាំ៧៥ ៧៤នេះឯង ។

ឈុនលី : ៧៤គេជម្លៀសពីភូមិនេះទៅនៅស្រេះ ។

វ៉ាត់ : ស្រេះ ។

ឈុនលី : ស្រេះហ្នឹងភូមិ?

វ៉ាត់ : ភូមិស្រេះនៅក្នុងឃុំអីគេ?

ឈុនលី : នៅព្រះនេត្រព្រះដូចគ្នា ។

វ៉ាត់ : គ្រាន់តែដូរភូមិ ។

ឈុនលី : ចុះអ៊ំអាចរៀបរាប់បានទេតាំងពីជំនាន់ លន់ នល់មក?

វ៉ាត់ : ហ្អស!ជំនាន់ លន់ នល់ ខ្ញុំមិនសូវចាំទេ ខ្ញុំចាំមិនបានផង ។

ឈុនលី : មុននឹងចូលដល់សម័យខ្មែរក្រហមហ្នឹងអ៊ំធ្វើអីគេចោះ?

វ៉ាត់ : ខ្ញុំនៅគេឲ្យលើកទំនប់ ។

ឈុនលី : មុនចូលរបបហ្នឹងណាស?

វ៉ាត់ : ហ្នឹងហើយគេឲ្យលើកទំនប់ណុងឯង ។

ឈុនលី : ឆ្នាំណា?

វ៉ាត់ : ឆ្នាំ៧៣ ៧៤នេះឯង ។

ឈុនលី : ៧៣ ៧៤គេឲ្យលើកទំនប់ហើយ?

វ៉ាត់ : លើកទំនប់ លើកទំនប់គេហៅស្ពានរាប ស្ពានកូនខ្វែង ខ្ញុំទៅកូនខ្វែងផង ។ អូស!ពិបាក តើគេឲ្យរែកទឹកឲ្យគេជីក ហើយកំលាំងខ្សោយពេកលើកដីឲ្យគេមិនបានពីរម៉ែត្រក៏ប្រធានក្រុមគេឲ្យរែកទឹក ខ្ញុំធ្វើការឡើងបាក់នោះណាស ។

ឈុនលី : ចុះកាលនោះមានបងប្អូនប៉ុន្មាននាក់?

រ៉ាត់ : ខ្ញុំមានបងប្អូនប្រាំនាក់ ។

ឈុនលី : ម្តាយឈ្មោះអី?

រ៉ាត់ : នេះម្តាយខ្ញុំ ។

ឈុនលី : ចាស!យាយឈ្មោះអីចេះ ខ្ញុំភ្លេចបាត់ហើយ?

រ៉ាត់ : យាយចាន់ ។

ឈុនលី : យាយចាន់ចឹងម៉ង ។ ឪពុកឈ្មោះកេតហ្នឹ?

រ៉ាត់ : គន ស្លាប់ហើយ ស្លាប់បានប៉ុន្មានឆ្នាំហើយ ។

ឈុនលី : ឈ្មោះអីគេ?

រ៉ាត់ : តា គន ។

ឈុនលី : ចុះឈ្មោះកេតហ្នឹងឈ្មោះតា?

រ៉ាត់ : តាកេតហ្នឹងតាខ្ញុំ ។

ឈុនលី : អីចឹងនៅនេះខ្មែរក្រហមចូលមកតាំងពីឆ្នាំណា?

រ៉ាត់ : តាំងពីឆ្នាំណាទេនាក វាភ្លេចទៀតណាស កាលនោះចូលឆ្នាំ៧៣ ៧៤ ៧២ទេដឹង...៧២ ហ្នឹងហើយ ៧២នេះឯង ។

ឈុនលី : ៧២ចូលមកដល់នេះ?

រ៉ាត់ : ដល់៧៥ ៧៦ នេះបានចាប់លើកទំនប់ ។

ឈុនលី : ៧៥ ៧៦បានចាប់ផ្តើមលើកទំនប់?

រ៉ាត់ : ចាស! ខ្មែរក្រហមចូល៧២នេះឯង ភ្លេច!ដល់យូរទៅចេះតែវង្វេងវង្វាន់អស់ហើយមិនបានគិតគូរអីទេ ។

ឈុនលី : ចុះអ៊ីខ្ញុំចង់ដឹងពីដំបូងមកពេលខ្មែរក្រហមចូលមកពីដំបូងឆ្នាំ៧២ ៧៣ ។ ចូលមកគេធ្វើម៉េចទៅ?

រ៉ាត់ : ចូលមកគេថាយើងហើយគំរាមយើងថាឲ្យធ្វើការឲ្យវា ។

ឈុនលី : និយាយប៉ុណ្ណឹង?

រ៉ាត់ : ចាស!

ឈុនលី : ចុះមីងថាអីទៅ?

រ៉ាត់ : មានថាអី បើឈឺក៏យើងរកថ្នាំលេបទៅ សន្លមកិច្ចមានបញ្ជូនទៅពេទ្យទៅ ។

ឈុនលី ៖ ហើយចូលមកគេរៀបចំជាសហករណ៍ហើយនៅកាលឆ្នាំ៧២ ។ ៧២ ឬ៧៣អ៊ី?

វ៉ាត់ ៖ ៧៣គេរៀបចំហើយសហករណ៍ ។

ឈុនលី ៖ ចឹងចូលមកប្រហែល៧២ហើយ?

វ៉ាត់ ៖ នោះឯង!ចុង៧២ហើយដំនាន់ ប៉ុល ពត ។

ឈុនលី ៖ ចូលមកគេឲ្យរៀបចំសហករណ៍?

វ៉ាត់ ៖ សហករណ៍ហូបបាយរួម ។

ឈុនលី ៖ សហករណ៍គេនៅកន្លែងណាទៅ?

វ៉ាត់ ៖ សហករណ៍ខ្ញុំកាលខ្ញុំជម្លៀសមកពីស្រេះគេឲ្យទៅនៅជើងវត្ត ភូមិខ្ញុំពីដើមនៅប៉ោយក្មៀង គេជម្លៀសខ្ញុំទៅជើងវត្តនៅសហរករណ៍ជើងវត្ត សហករណ៍នៅខាងកើតថ្នល់ជើងវត្ត នោះឯងគេដាក់ស្អីៗ ។

ឈុនលី ៖ កាលនោះចូលមកគេបំបែកគ្រួសារម៉េងហ្អី?

វ៉ាត់ ៖ បំបែក ។

ឈុនលី ៖ ចូលមកភ្លាមបំបែកម៉េងហ្អី?

វ៉ាត់ ៖ ចាស!បំបែកគ្រួសារទៅជាក្រុម ។

ឈុនលី ៖ អាចថារយៈពេលប៉ុន្មានទៅបំបែកគ្រួសារ?

វ៉ាត់ ៖ បំបែករយៈពេលយូរដែរណាស បំបែកឲ្យធ្វើការជាក្រុមៗ ។ បើថាអ្នកវ័យកណ្តាលក៏ឲ្យធ្វើការស្រាលៗ បើកំលាំងខ្លាំងទៅធ្វើការលើកទំនប់ទៅហើយយាយនៅផ្ទះជំរះស្មៅទៅ ។

ឈុនលី ៖ ហើយដូចអ៊ីចឹងគេឲ្យទៅលើកទំនប់?

វ៉ាត់ ៖ ចាស!

ឈុនលី ៖ អ៊ីថាទំនប់អីគេទេ...

វ៉ាត់ ៖ គេហៅទំនប់ស្ពានរាប ទំនប់កូនខ្វែងគេឲ្យទៅលើក ។

ឈុនលី ៖ កូនខ្វែង?

វ៉ាត់ ៖ ចាស!កូនខ្វែងឯងជើង ។ ម៉ាអាទិត្យអត់ទឹកម៉ាអាទិត្យដល់មកមានទឹកនៅព្រៃមាន់នាំគ្នាមុជទឹក ហើយទៅគេឲ្យទៅប៉ោយសំរោងទៀត លើកទំនប់ប៉ោយសំរោងទៀត ។

ឈុនលី ៖ ចឹងកាលនោះមានប្រជាជនមកពីស្រុកភូមិណាទៀតទេដែលទៅលើកទំនប់លើកអី?

វ៉ាត់ ៖ ប្រជាជនថ្មីមានតើអ្នកដែលគេមកពីឆ្ងាយដែលគេជម្លៀសមកនោះ ។

ឈុនលី ៖ ភាគច្រើនមកពីណាខ្លះ?

ភាត់ : មកពីខាងប៉ែកស្វាយ បាត់ដំបងនេះហើយនៅជុំគ្នា លើកជុំគ្នាលាយគ្នាជាមួយប្រជាជនចាស់ ។ អ្នកណាដែលស្គមស្គាំងហូបបាយមិនបានក៏ចេះតែឈឺស្មេកស្មុក់ពិបាកណាស់ ។

ឈុនលី : ចុះអ្នកណាគេអ្នកគ្រប់គ្រងឲ្យទៅលើកទំនប់លើកអីហ្នឹង?

ភាត់ : មេគេនោះឯង ។

ឈុនលី : ស្គាល់ទេអ៊ំ? ដែលថាទៅលើកទំនប់ស្ពានរាបហ្អី?

ភាត់ : ស្ពានរាប ។

ឈុនលី : អ្នកណាគេអ្នកកាន់នៅនេះ?

ភាត់ : សុទ្ធតែមេៗស្លាប់អស់ហើយ ។

ឈុនលី : អីចឹងស្លាប់អស់ហើយ?

ភាត់ : ស្លាប់អស់ហើយ ។

ឈុនលី : ឈ្មោះអីខ្លះទៅអ៊ំ?

ភាត់ : ឈ្មោះ ពូថង ។

ឈុនលី : ថង ហ្នឹងគាត់ធ្វើអីគេ?

ភាត់ : ធ្វើខាងដឹកនាំទំនប់នេះឯង ។

ឈុនលី : អាចថាឋានៈគាត់ជាអីគេ មេភូមិ មេឃុំ?

ភាត់ : នេះក្តោបក្តាប់យើងនៅក្នុងភូមិ ។

ឈុនលី : របៀបថាមេភូមិហ្អី?

ភាត់ : ហ្នឹងឯង អ្នកណាត្រូវទៅណាក៏ទៅៗ ។

ឈុនលី : ចុះបងប្អូនប្អូននាក់ទៀតរបស់អ៊ំទៅណាទៅ?

ភាត់ : ប្អូនខ្ញុំនៅ វានៅតូចអត់បានទៅណាទេ បើបានទៅបានទៅតែប្អូនខ្ញុំមីស្រីតូចដែលឈរនៅនេះមិញ វាបានប្តីបានអី ។ ក្រៅពីនោះនៅតូចៗគេឲ្យនៅកុមារលើកអាចម៍គោអាចម៍អី ។

ឈុនលី : ចឹងអ៊ំបងគេហ្អី?

ភាត់ : បងគេ ។

ឈុនលី : អាយុប៉ុន្មានទៅកាលនោះ?

ភាត់ : ខ្ញុំកាលនោះអាយុ៣៥ ៣៦ ។

ឈុនលី : ម្តេចស្រាម?

វ៉ាត់ : ៣៦កាលនោះ ។

ឈុនលី : អឺចឹងឥឡូវហុកហើយ!

វ៉ាត់ : សព្វថ្ងៃ៥៧ ។

ឈុនលី : ចឹងកាលនោះ២៧ទេហ្អី ព្រោះអីតាំងពីសម័យខ្មែរក្រហមមកសាមសិបឆ្នាំហើយឡូបអឹ ៥៧ អឺចឹងកាលនោះ២៧ឆ្នាំ ។

វ៉ាត់ : ខ្ញុំញាក់ពេញបីខែនោះពុកម៉ែខ្ញុំនេះញាក់ ។

ឈុនលី : ចុះកាលនោះអឹងអត់ទាន់មានគ្រួសារទេហ្អី?

វ៉ាត់ : អត់ទេ ខ្ញុំអត់មានទេ ។

ឈុនលី : មកដល់ឥឡូវអត់មានដែរ?

វ៉ាត់ : អត់ទេ ។ គេឲ្យទៅដស្ទូងដកនៅខាងកើតអូរនេះឯង ស្ទូងដកដល់ពេលញាក់មកវិញ ដល់សំរាកញាក់ទៅទៀត ញាក់មកវិញ ។ គេមិនឲ្យនៅឯណា តែនៅអត់របបស៊ី បានថ្នាំដឹកដល់ទៅបានជា ។ នឹងសាច់ឆ្អែ បានសាច់ឆ្អែហូបបានបាត់ញាក់ ។ និយាយត្រង់ទៅបានត្រូវចំណីនឹងសាច់ឆ្អែ បើបានសាច់ឆ្អែដូចកាលពីសង្គមឆ្ងាញ់បាត់ហើយ ដល់ខ្ញុំហូបទៅបាត់ដែរបាត់ញាក់ ។

ឈុនលី : ចុះកាលទៅលើកទំនប់នៅនោះហូបចុកអីយ៉ាងម៉េចទៅ?

វ៉ាត់ : ហូបចុកមានអីបបូរតើអូន យ៉ាប់នឹងនៀយ លំបាកបន្តិចហ្នឹងឯង ។

ឈុនលី : ពិបាកម៉េចខ្លះទៅអ៊ំ?

វ៉ាត់ : តែកំលាំងខ្សោយហើយទៅធ្វើការ...បើយើងឈឺហើយយើងទៅប្រាប់មេការទៅថាខ្ញុំធ្វើការមិនកើតទេ លើកទំនប់មិនកើតទេ ឈឺក៏សំរាកទៅគេឲ្យហូបបបរបួបអីទៅ ។

ឈុនលី : កាលនោះទៅគ្នាច្រើនទេទៅលើកទំនប់?

វ៉ាត់ : ច្រើន រាប់រយរាប់ពាន់នាក់ច្រើនណាស់ដែលទៅនោះ ។ ម៉ាក្រុមដប់នាក់ៗទាំងចាស់ទាំងថ្មី ។

ឈុនលី : អ្នកប្រជាជនថ្មីទៅដែរ?

វ៉ាត់ : ចាស!ទៅ ឲ្យទៅដែរ ជុំតែគ្នា ។ អាណាដែលមិនសូវសកម្មការងារ យ៉ាប់ទៅក៏នៅខ្លះទៅ អ្នកណាដែលគ្រុនញាក់គ្រុនញ័រទៅ ។ បើថាគ្រុនមែនទែនទៅក៏បានហូប អ្នកណាដែលគ្រុនបន្ទំទៅក៏មិនបានហូបទៅ ។

ឈុនលី : ទំនប់ហ្នឹងគេហៅអីគេទៅ?

ភាត់ : គេហៅប្រពាំងថ្ម ៗ

ឈុនលី : អត់ទេ ទំនប់ស្ពានរាបហ្អី?

ភាត់ : ទំនប់ស្ពានរាបកំពស់៦០ម៉ែត្រ ខ្នង៣០ម៉ែត្រ ។

ឈុនលី : អាហ្នឹងផ្សេងពីត្រពាំងថ្មតើហ្អី?

ភាត់ : ទេ!គេថាស្ពានរាប ៗ ហើយត្រពាំងថ្មដូចគ្នាទេដឹង!

ឈុនលី : អីចឹងត្រពាំងថ្មហ្នឹងជីកយូរហើយចឹង?

ភាត់ : យូរហើយតាំងពីលើកនោះឯង ។

ឈុនលី : តាំងពី៧៨ហ្នឹង?

ភាត់ : នោះឯង ។

ឈុនលី : មិនមែន៧៦អីទេ? ស្ពានរាបហ្នឹងពីមុនមកគេហៅស្ពានរាបចឹងហ្មងហ្អី?

ភាត់ : ស្ពានរាប ។ អីចេះឯង គេថាបើអ្នកណាចង់ទៅលើកទំនប់ស្ពានរាបត្រពាំងថ្មអីទៅ ហើយបើខ្ញុំ អត់ជាដើងអត់ទៅទេ ស្អម ឈឺអីឈឺ ។ ប្រធានសហករណ៍គេថាកុំទៅអី ។

ឈុនលី : ប្រធានសហករណ៍ឈ្មោះអីទៅ?

ភាត់ : សហករណ៍ឈ្មោះរ៉ឺ ។

ឈុនលី : ស្រីហ្អី?

ភាត់ : ស្រី ។

ឈុនលី : ឈ្មោះរី?

ភាត់ : ចាស!ស្រី ។

ឈុនលី : មកពីខាងនិរតី?

ភាត់ : និរតី ។

ឈុនលី : គាត់និរតីចឹងគាត់មកក្រោយទេហ្អី? គាត់មកឆ្នាំណា?

ភាត់ : មិនដឹងឆ្នាំណាទេអូន អឺវាភ្លេចដែរនោះបើអឹមិនបានដាកត់ទុក មិនដឹងឆ្នាំណាឆ្នាំប៉ុន្មានផង ។

ឈុនលី : ប៉ុន្តែខ្ញុំដូចជាឆ្ងល់បន្តិចអឹ ៧៨ហ្នឹងជីកទំនប់ត្រពាំងថ្ម ហើយអាស្ពានរាបហ្នឹងផ្សេងទេហ្អី? ផ្សេងពីអាត្រពាំងថ្មឬយ៉ាងម៉េច?

ភាត់ : គេថាស្ពានរាប ៗ ខ្ញុំក៏ថាតាមគេទៅ គេថាឲ្យទៅលើកនៅស្ពានរាបក៏ទៅលើកនៅស្ពានរាបទៅ ។

ឈុនលី : អីចឹងតាំងពីរបបខ្មែរក្រហមមកអ៊ីធ្លាប់ដឹកទំនប់ប៉ុន្មានទំនប់?

វ៉ាត់ : ខ្ញុំទើបតែដឹកបានពីរទំនប់នេះឯង ។

ឈុនលី : ទំនប់អីគេខ្លះ?

វ៉ាត់ : ទំនប់ត្រពាំងថ្ម ហើយទំនប់កូនខ្វែង ។

ឈុនលី : បើចឹងទៅកូនខ្វែងមុន?

វ៉ាត់ : កូនខ្វែងទៅក្រោយ ដល់កូនឯងសួរអ៊ីចឹងអ៊ី...នេះដែរបើអ៊ីមិនចាំ ដល់ចឹងទៅភ្លេចភ្លាំង ។ បើកាលសម័យនោះខុសអីយកទៅវ៉ៃចោល ភ្លេចភ្លាំងស្មារតីខុសត្រូវៗដល់ចឹងទៅចេះតែភ្លេចៗ ។ ចាំតែគោលៗ បើថាយ៉ាប់អស់កំលាំងខ្លាំងបើគេឲ្យលើកទំនប់ ។

ឈុនលី : ស្ពានរាប អាហ្នឹងជាភូមិ?

វ៉ាត់ : នោះឯងបើទិសគេឲ្យទៅលើកចុះឯង ។

ឈុនលី : តែចង់និយាយថាអាហ្នឹងជាភូមិឬជាឃុំឈ្មោះអីស្ពានរាបហ្នឹង ។

វ៉ាត់ : ដូចជាឃុំ សព្វថ្ងៃមានផ្ទះច្រើនហើយ បើកាលអ៊ីលើកនោះអត់មានផ្ទះទេ វាល មើលទៅលើចង់ផុតក ។

ឈុនលី : ចា៎!ចង់និយាយថាអាហ្នឹងវានៅឆ្ងាយពីនេះទេស្ពានរាបហ្នឹង?

វ៉ាត់ : ឆ្ងាយតើអូន ស្ពានរាបនៅនឹងត្រពាំងថ្មហ្នឹងឯងជាប់គ្នានឹងឯង ។

ឈុនលី : ជាប់គ្នាឬក៏ផ្សេងគ្នា?

វ៉ាត់ : ពួគេថាស្ពានរាបៗ ។

ឈុនលី : ចឹងទាល់តែឃុំ?

វ៉ាត់ : មិនដឹងឃុំអីគេទេខ្ញុំមិនសូវដឹងផង ។

ឈុនលី : ហើយកាលនោះមនុស្សរាប់ពាន់នាក់ម៉្ងៃ?

វ៉ាត់ : ចា៎!

ឈុនលី : ហើយអ៊ីថាចាប់ផ្ដើមដឹកហ្នឹងចាប់តាំងពីឆ្នាំ៧៨?

វ៉ាត់ : ឆ្នាំ៧៨ ៧៣ ៧៨នេះឯង ។

ឈុនលី : អ្នកណាគេអ្នកដឹកនាំដឹកដីហ្នឹង?

វ៉ាត់ : សុទ្ធតែពួកគេអ្នកនិរតីអ្នកអីហ្នឹងគេឲ្យយើងទៅលើកចេះតែទៅលើកទៅណាស ។

ឈុនលី : កាលនោះនិរតីមកក្រោយពេលចាប់ខ្លួនអ្នកនៅនេះហើយទេហ្អី? ចុះពីដំបូងមកអ្នកណាអ្នកកាន់កាប់មុនពេលនិរតីចូលមក ។

វ៉ាត់ : ពួកពាយ័ព្យ ពួកតាក្រុកពួកអីនេះ ពួកពាយ័ព្យហ្នឹងឯងពួកតាក្រុក ខ្ញុំមិនសូវដឹងផងពួកពាយ័ព្យហ្នឹងពួកតាក្រុក ។

ឈុនលី : តាក្រុក ហ្នឹងអ្នកហ្នឹងម៉េងហ្អី?

វ៉ាត់ : អ្នកស្រុកឆ្ងាយ ពួកពាយ័ព្យ ពួកនិរតី ពួកនិរតីពួក រី ប្រធានសហករណ៍ប្រធានអីហ្នឹង ។

ឈុនលី : រី ហ្នឹងប្រុស?

វ៉ាត់ : ស្រី ។

ឈុនលី : បើ តាក្រុក នេះបានប្រុស ។

វ៉ាត់ : ខ្ញុំបើសួរអារឿងនិរតីពាយ័ព្យនេះ មិនសូវអាប្រសព្វនិយាយផង ។

ឈុនលី : អត់សូវដឹងឬក៏ក្មេច?

វ៉ាត់ : អត់សូវដឹង ហើយភ្លេច ។ កាលសម័យនោះសម័យវិវរបបផង កាលទៅនៅស្រែះនោះអ្នកណាខុសច្បាប់ខុសអីដាក់ផសៗម៉េង គេជម្លៀសទៅនៅស្រែះនោះ ។

ឈុនលី : ជម្លៀសនៅស្រែះហ្នឹងធ្វើអីគេ?

វ៉ាត់ : អានេះឯងដែលយើងចេញពីភូមិប៉ោយក្លឿងទៅនៅស្រែះ ។

ឈុនលី : នៅស្រែះហ្នឹងធ្វើអី?

វ៉ាត់ : អត់មានធ្វើការអីទេ អត់មានធ្វើអីទេ ។ នៅបើយើងធម្មតានៅធ្វើចំការធ្វើអីទៅ ស៊ីទៅដាំហូបទៅ ។

ឈុនលី : បែកគ្នាអី ដាក់សហករណ៍ហើយនៅ?

វ៉ាត់ : នៅអត់ទាន់ដាក់ទេ ហើយបើខែអាវពណ៌អីគេឲ្យជ្រលក់ឲ្យខ្មៅអស់ឲ្យយើងស្លៀកពាក់ ។

ឈុនលី : ចឹងកាលនៅស្រែះហ្នឹងនៅជាមួយឪពុកម្ដាយដែរ?

វ៉ាត់ : នៅជុំទាំងអស់គ្នា ។

ឈុនលី : រស់នៅរបៀបផ្ទះម៉េងហ្អី?

វ៉ាត់ : ផ្ទះអី នៅខ្ទម ធ្វើខ្ទមដផ្ទៃគ្នាវែងតទៅណាស ។

ឈុនលី : ហើយហូបចុកអីរៀងខ្លួន?

វ៉ាត់ : រៀងខ្លួន ។

ឈុនលី : គេចែករបបឲ្យ?

វ៉ាត់ : ចែក ដផ្ទៃគ្នាវែងតម៉ាជួរៗ ។

ឈុនលី : ចឹងកាលនោះអត់ទាន់ទៅលើកទំនប់ទេ?

រ៉ាត់ : អត់ទាន់ទៅទេ ។

ឈុនលី : ចឹងទៅនៅស្រែះហ្នឹងឆ្នាំណា?

រ៉ាត់ : បើឆ្នាំ៧៣ ៧៤ ហ្អឺ៧២ទេអូនហ្អាស អឺក្មេងហ្អាសមិនបានចំណាំអីទេកត់ទុកអីទេ គេឲ្យចេញក៏ចេញទៅ ។

ឈុនលី : ចុះដល់ពេលចេញពីស្រែះមកទៅនៅឯណាទៀត?

រ៉ាត់ : ចេញពីស្រែះមកគេឲ្យទៅនៅរន្ទះបាញ់ ។

ឈុនលី : អាហ្នឹងជាភូមិហ្អី?

រ៉ាត់ : អត់មានភូមិទេ វាលណាស ។

ឈុនលី : អាហ្នឹងនៅក្នុងភូមិអីគេ?

រ៉ាត់ : អត់មានភូមិទេ វាលរន្ទះបាញ់អត់មានភូមិទេ ។

ឈុនលី : ចា៎!ប៉ុន្តែវានៅជិតស្រែះ?

រ៉ាត់ : ជិតស្រែះនៅឯកើតណោះ ។

ឈុនលី : ឥឡូវហ្នឹងនៅក្នុងភូមិអីគេរន្ទះបាញ់? វាលរន្ទះបាញ់ហ្នឹងនៅក្នុងភូមិអីគេ?

រ៉ាត់ : ភូមិហៅថាភូមិរន្ទះបាញ់ហ្នឹងហើយបើអត់មានមនុស្សនៅផង ។

ឈុនលី : ចុះទៅនៅនោះធ្វើអីទៅ?

រ៉ាត់ : ចុះបើគេឲ្យយើងទៅនៅ ។

ឈុនលី : នៅយ៉ាងម៉េចបើសុទ្ធតែវាល?

រ៉ាត់ : ចុះបើនៅយូរបានប៉ុន្មានហើយបានគេឲ្យជម្លៀសទៅនៅជើងវត្តណោះ ។

ឈុនលី : ជើងវត្តហ្នឹងភូមិហ្អី?

រ៉ាត់ : ភូមិជើងវត្ត ។

ឈុនលី : នៅជើងវត្តហ្នឹងនៅធ្វើអីគេ?

រ៉ាត់ : យើងធ្វើការ បើកំលាំងមានយើងធ្វើចំការធ្វើអីទៅ ។

ឈុនលី : ចំការដល់ណាទៅអឹ?

រ៉ាត់ : ចំការនៅម៉ាជួរត្រពាំងកក់ត្រពាំងអីនេះណាសដាំដំឡូងមី ដាំអី ដំឡូងជ្វាហូបទៅ ។

ឈុនលី : កាលនោះគេហូបជាសហករណ៍ហើយនៅ?

រ៉ាត់ : រួមហើយ ធ្វើសហករណ៍នៅនេះរួមហើយ ។

ឈុនលី : អាហ្នឹងប្រហែលឆ្នាំណាអ៊ឹហ្ន៎?

ភាត់ : មិនដឹងឆ្នាំណាទេ អ៊ីមិនដឹងឆ្នាំណាដែរនេះ ឯងវាចាំមិនច្បាស់វល់តែភ្លេចភ្លាំង បើគេអ្នកចេះទៅប្រុយ ៗ មកចូលជើងវត្តនេះបានគេវៃរបប ៗ

ឈុនលី : វៃរបបម៉េចទៅ?

ភាត់ : វៃ អ្នកណាខុសច្បាប់ខុសអី ៗ អាកាលអ៊ីទៅធ្វើចំការដំឡូងមីនៅនោះណាស វាយកឯងទាំងខ្សែៗទៅយកមកចងវៃ ដល់តែប្រធានគេថាទុកគាត់ទៅកសាងទៀតទៅ កុំធ្វើបាបគាត់ ចឹងក៏ឈប់ទៅ ៗ បានគាត់នេះឯងកុំអីយកទៅកសាងហាហុកសិបនាក់ណាសកាលនោះ ៗ

ឈុនលី : ខ្ញុំអត់ទាន់កន្លែងអ៊ីថាមកដល់ជើងវត្តវៃរបបម៉េចវិញ?

ភាត់ : ចែករបប ចុងភៅគេចាត់ ចុងភៅគេធ្វើ យើងមកពីធ្វើការក៏គេឲ្យយើងចានម្នាក់មួយៗទៅយករបប ៗ

ឈុនលី : ចុះប្រជាជនថ្មីដែលមកពីកន្លែងផ្សេងៗទៀតមកនេះឆ្នាំណា?

ភាត់ : ហ៊ឺស!ខ្ញុំក៏មិនដឹងឆ្នាំដែរ ៗ

ឈុនលី : ហ្នឹងអ៊ីនៅឯណាហើយដែលប្រជាជនថ្មីមក?

ភាត់ : នៅជើងវត្ត ៗ

ឈុនលី : ចឹងពេលនោះប្រជាជនថ្មីចាប់ផ្ដើមមកហើយ?

ភាត់ : ចាស!មកហើយ ៗ

ឈុនលី : ចុះអាកាលនៅស្រែះហ្នឹងមានប្រជាជនថ្មីមកហើយនៅ?

ភាត់ : ប្រជាជនថ្មីមិនទាន់មកទេ អត់ទាន់មកទេ នៅតែប្រជាជនចាស់នៅភូមិចៅយក្លឿង ៗ

ឈុនលី : ប្រហែល៧៥ទេហ្អី ព្រោះឆ្នាំ៧៥ថ្ងៃ១៧ មេសាហ្នឹងមិនខ្មែរក្រហមមកដល់ភ្នំពេញ អ៊ីដឹងរឿងទេពេលខ្មែរក្រហមចូលមកដល់ភ្នំពេញដំបូង?

ភាត់ : អូនឯងសួរ អ៊ីក៏យ៉ាប់ដែរ ៗ

ឈុនលី : អ៊ីអត់ចាំហ្អី?

ភាត់ : អត់ចាំបានផង ៗ

ឈុនលី : ចឹងខ្ញុំសួរអីចេះវិញ ពេលអ៊ីមកនៅជើងវត្តបានរយៈពេលប៉ុន្មានបានគេឲ្យទៅជីក?

ភាត់ : នៅជើងវត្តគេឲ្យទៅលើកទំនប់ដែរ តែអត់ទាន់ចេញទេ ៗ

ឈុនលី : ទំនប់អីគេអាហ្នឹង?

ភាត់ : ទំនប់នោះឯង ទំនប់ដែលអ៊ីថានោះឯង ៗ

ឈុនលី : ប៉ុន្តែពេលនោះនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ណ្យទេតើហ្អី ?

ភាត់ : និរតី ។

ឈុនលី : ចុះពេលណាបានភូមិនេះគ្រប់គ្រងដោយពួកពាយ័ព្យ?

ភាត់ : ពួកពាយ័ព្យ តាក្រុក ក៏មិនដឹង បែបតាក្រុកហ្នឹងឯង ។

ឈុនលី : ចុះមេ តាក្រុក ហ្នឹងទៀតឈ្មោះអីគេ?

ភាត់ : មេតាក្រុកខ្ញុំក៏មិនសូវដឹងដែរណាសអូន គេថាឲ្យទៅលើកទីនោះក៏ទៅៗណាស មិនដឹងថាមេណាទេ ។

ឈុនលី : ចុះឈ្មោះ មោងមានទេ?

ភាត់ : មោង?

ឈុនលី : តាមោង!

ភាត់ : តាមោង!ឮតែគេថាឈ្មោះមោងៗ តែមិនដឹងតាមោងនោះគាត់នៅឯណាណាស ខ្ញុំមិនដឹងដែរ ។

ឈុនលី : តែឮដែរ?

ភាត់ : ចាស!តែខ្ញុំមិនដឹងមោងណានោះណាស បើខ្ញុំអត់ស្គាល់ដែរ គេថាទៅលើកទំនប់ក៏ទៅៗ ។

ឈុនលី : ចឹងកាលតាក្រុក នៅគ្រប់គ្រងហ្នឹងអឹអត់ទាន់ទៅលើកទំនប់ទេ?

ភាត់ : ដែលតាក្រុកមក ខ្ញុំលើកហើយ លើកបណ្ដើរណាសអូន គាត់ថាឲ្យទៅលើកទំនប់ ។

ឈុនលី : ចឹងពេលដំបូងគេកំណត់យ៉ាងម៉េច? លើកប៉ុន្មានម៉ែត្រអាហ្នឹង?

ភាត់ : ដំរៅពីរម៉ែត្រ ម៉ាម៉ែត្រកន្លះ ដោយកន្លែង ។

ឈុនលី : ពេលគេដឹកហ្នឹងគេប្រាប់យ៉ាងម៉េចទៅ? គ្នាច្រើន?

ភាត់ : ច្រើនណាស់ ឡើងគ្នារដែតដឹកនោះណាស ។

ឈុនលី : ទាំងថ្មីទាំងចាស់?

ភាត់ : ចាស!ទាំងថ្មីទាំងចាស់ ។

ឈុនលី : ហើយមានតែប្រជាជនសុទ្ធហ្អី អត់មានខ្មែរក្រហមអីទេហ្អី?

ភាត់ : អត់ទេ មានតែខ្មែរយើង ។

ឈុនលី : ប្រជាជនធម្មតាទេ?

ភាត់ : ប្រជាជនធម្មតាលើកដង្ហែគ្នា ដឹកដង្ហែគ្នារដែត ។

ឈុនលី : គេមានប្រាប់ទេថាផែនការគេដឹកប៉ុន្មានលើកម្នាក់ប៉ុន្មាន?

វ៉ាត់ : ម៉ាម៉ែត្រកន្លះ ជួនកាលពីរម៉ែត្រ ពីរម៉ែត្រហ្នឹងហើយអូន ។

ឈុនលី : ពីរម៉ែត្រការហ្អី?

វ៉ាត់ : ចាស!

ឈុនលី : ម្នាក់?

វ៉ាត់ : ម្នាក់ ហើយបើកំលាំងគ្នាខ្សោយកំលាំងគ្នាស្គមស្គាំងលើកម៉ាម៉ែត្រអត់ចង់រួចទេណាស ក្នុងម៉ាដៃហ្នឹងលើកអត់ចង់រួចទេ ។

ឈុនលី : លើកបន្តៗគ្នាចឹងទៅ?

វ៉ាត់ : បណ្តើរគ្នាទៅម៉ាជួរៗចឹងទៅ ។

ឈុនលី : ចុះបណ្តោយអាងហ្នឹងប៉ុន្មានម៉ែត្រទៅ?

វ៉ាត់ : បើស្ពានថ្មនេះគេថាកំពស់៦០ម៉ែត្រ ទឹង៣០ម៉ែត្រ ។

ឈុនលី : កំពស់ កំពស់មិនជំរៅ?

វ៉ាត់ : កំពស់៦០ម៉ែត្រ ។

ឈុនលី : ជំរៅហ្នឹង?

វ៉ាត់ : ទេ កំពស់វាឡើងទៅចាក់នៅឯលើទៀតណាសអូន លើកឡើងលើទៅឃើញតែមនុស្សតូច លើកឡើងទៅលើទៀតណាស ។

ឈុនលី : ចាំ!ប៉ុន្តែអាហ្នឹងគេហៅជំរៅទេហ្អី?

វ៉ាត់ : បើជំរៅវាចូលជិតពីរម៉ែត្របីម៉ែត្រទៅដឹងគិតជំរៅនោះ ។

ឈុនលី : ចុះកំពស់' ៦០ម៉ែត្រហ្នឹងគេវាស់ពីណាទៅណា?

វ៉ាត់ : ពីក្រោមហ្នឹងក្រោមលើដីប្ញក្រោមបាត ។ ទេ អាលើដីនេះឯងកំពស់ទៅលើ ។

ឈុនលី : ចុះគេជីកឡើងទៅលើធ្វើអី៦០ម៉ែត្រខ្ពស់សឹងអី?

វ៉ាត់ : គេថា កំពស់៦០ម៉ែត្រ ខ្នង៣០ម៉ែត្រ ។ ឃើញតែភ្នំនោះឯងដែលខ្ពស់ បើថាទំនប់កូនខ្វែងនោះទាបទេខ្នងតែប៉ុន្មានម៉ែត្រទេ ។ ហើយគេឲ្យខ្ញុំទៅរែកទឹកឆ្ងាយណាស់ រែកទឹកទំរាំតែមកដល់ថ្ងៃម៉ោង១ម៉ោង២បានមកដល់ផ្ទះដល់កន្លែងដេក ។ រែកបំពង់ រែកយប់ថ្ងៃណាទៅដល់ល្ងាច យប់ពពឹមពពើមងងឹតមាន់ ។ ខ្ញុំងងឹតមាន់ ងងឹតមាន់ច្រើនណាស់ គេឲ្យលើកម៉ាជួរទៅអ្នកណាងងឹតមាន់ហុចឲ្យគ្នាទៅ អ្នកណាគេមិនងងឹតគេលើកបោះលើកបោះទៅ ។ ឯងល្ងឹតក៏ចាប់ដៃគ្នាបោះទៅ គេធ្វើបាបណាស់ងងឹតមាន់ ។ ងងឹតមាន់ពេលថ្ងៃវា

ស្រវាំង១ ត្រូវនឹងយប់ទៀតមើលមិនឃើញ ថាវេទនាណាស់ ។
ធ្វើការនោះគេមិនឲ្យហូបបបូរទេ ។

ឈុនលី : ចុះហេតុអីបានគេឲ្យលើកឡើងកំពស់៦០ម៉ែត្រ?

រ៉ាត់ : គេទប់ទឹក ។

ឈុនលី : ដំបូងដីកន្លែងទំនប់ហ្នឹងគេធ្វើអីវិញ?

រ៉ាត់ : កាលនោះដីនៅរាប និយាយទៅខ្ញុំមិនដែលបានជាបានយូរទេមកផ្ទះវិញ ។

ឈុនលី : ធ្វើការនៅនោះបានប្រហែលប៉ុន្មាន?

រ៉ាត់ : បានប្រហែល២ខែនោះឯងឈឺក៏មកវិញដែលគេនៅលើកក៏លើកបន្តទៀតទៅមិនសូវដែល លើកជាប់ទេបើឯងអត់ស្រួល ។

ឈុនលី : ប៉ុន្តែធម្មតាអ៊ំទៅពីដំបូងមិនដឹងហ្នឹងនៅរាប អីចឹងគេមិនប្រាប់ថាគេចង់បានប្រវែងប៉ុន្មាន ទទឹងប៉ុណ្ណេះ បណ្តោយវាប៉ុន្មានចឹងណាស គេអត់និយាយទេ?

រ៉ាត់ : អត់ដែលបាននិយាយផង វាភ្លេចផងមិនបានទេអូនអើយ ។

រ៉ាត់ : វែកជាមួយមីប្អូននោះឯង មីប្អូនឈ្មោះ រៀន ទៅវែកទឹកជុំគ្នានៅកូនខ្វែង ។

ឈុនលី : កូនខ្វែងហ្នឹងក្រោយត្រពាំងថ្មទៀត?

រ៉ាត់ : ក្រោយ ។

ឈុនលី : ចុះអ៊ំម្នាក់ឯងចឹងគេឲ្យជីកប៉ុន្មាន?

រ៉ាត់ : ពីរម៉ែត្រ ។

ឈុនលី : អាហ្នឹងយើងកំលាំងមាំមួនហ្អី?

រ៉ាត់ : ចា៎!កំលាំងមាំមួន ដល់តែយើងមើលទៅកំលាំងកាន់តែខ្សោយកាន់តែអន់គេឲ្យម៉ាម៉ែត្រ ហើយកន្លះម៉ែត្រទៀតនៅតែជីកមិនបានទៀតហ្នឹងណាស កាន់តែយ៉ាប់ ។

ឈុនលី : ហើយពីដំបូងអ៊ំជីក ជីកយកទៅដាក់នៅឯណាដី?

រ៉ាត់ : ដាក់ទៅលើនោះណាសអូន ។

ឈុនលី : ដាក់ទៅលើ?

រ៉ាត់ : ហ្នឹងហើយវែកដាក់ទៅលើឡើងដាក់ទៅលើទៀត ។ គេក៏វែកយើងក៏វែកទៅណាស ។

ឈុនលី : គោលបំណងគេធ្វើអីគេខ្ពស់ចឹងឆ្ងល់ដល់ហើយ?

រ៉ាត់ : ខ្ញុំមិនដឹងដែរគេថាឲ្យលើកទំនប់ក៏លើកទៅណាសអូន ។

ឈុនលី : កន្លែងនោះគួរតែមានទឹកអីបានធ្វើទំនប់?

វ៉ាត់ : គេថាទឹកត្រពាំងថ្មៗមិនឃើញទេឡូល្ងាច ។

ឈុនលី : តែកាលពីដើមក្រែងអត់មានឯណាហ្អី?

វ៉ាត់ : ពីដើមមិញបែបមិនមានទេដឹង?

ឈុនលី : តែពេលអ៊ំទៅធ្វើការដំបូងមានទឹកទេ?

វ៉ាត់ : អត់ អានេះទើបចាប់ផ្ដើមបានមានទឹកបេះណាអូន! កាលអ៊ំទៅលើកមានទឹកអីទាល់តែអ៊ំទៅលើកនេះហើយ ។

ឈុនលី : អីចឹងប្រវែងអីអត់ដឹងទេ?

វ៉ាត់ : អត់ដឹងទេ ហ្អូស!ខ្ពស់ណាស់ ។

ឈុនលី : តែបើតាមអ៊ំដឹងកំពស់ប៉ុន្មានក្រោយមក?

វ៉ាត់ : ទាល់តែខ្ញុំជាគេមកវិញគេថាកំពស់៦០ម៉ែត្រ ។

ឈុនលី : ហើយជំរៅវានោះ?

វ៉ាត់ : ជំរៅមិនបានសួរគេទេ ។

ឈុនលី : ហើយទទឹងបណ្ដោយអីនោះ?

វ៉ាត់ : ទទឹងបណ្ដោយវែងណាស់ ។

ឈុនលី : ប្រហែលប៉ុន្មានទៅ?

វ៉ាត់ : បើលើកគ្នាឡើងម៉ាជួរហើយមកណោះទៀតមនុស្សមិនតិចទេណាស រាប់រយរាប់ពាន់នាក់ណាសមិនតិចទេមើលទៅឡើងព្រាត ។

ឈុនលី : កំពស់៦០ម៉ែត្រខ្ពស់ណាស់ណាអ៊ំ?

វ៉ាត់ : ណុងឯងកំពស់៦០ម៉ែត្រខ្ពស់ ខ្ញុំង៣០ខ្ពស់ងើយមើលទៅឡើងនេះទៅណាស ។

ឈុនលី : ហើយឡើងម៉េចទៅអាពេលលើកដីឡើង?

វ៉ាត់ : ឡើងតាមអាយើងជីកកន្ទាក់ៗឡើងទៅណាស វេទនាណាស់សម័យនោះ ។

ឈុនលី : កន្ទាក់ហ្នឹងឡើងមកលើដីយើងស្មើហ្នឹង...

វ៉ាត់ : វែកឡើងទៅលើណាស ។

ឈុនលី : ឡើងទៅលើដីទៀត?

វ៉ាត់ : ឡើងទៅចាក់នៅឯលើទៀតចុះវែកចាក់ៗនៅឯលើហ្នឹងគេក៏វែកចាក់ទៅ យើងក៏វែកចាក់ទៅបណ្ដើរៗគ្នាទៅណាស ។ ថាសម័យនោះបើតស៊ូមកដល់សព្វថ្ងៃនេះសំណាងហើយ ខ្ញុំនៅតែនឹងទំនប់នោះឯង ។

ឈុនលី ៖ ចុះអីឈើ?

វ៉ាត់ ៖ ឈើ!

ឈុនលី ៖ ចឹងឈើសុំគេមកវិញ?

វ៉ាត់ ៖ ចាស!សុំឈប់សុំគេមកវិញ ។

ឈុនលី ៖ គេអត់ថាអីទេ?

វ៉ាត់ ៖ អត់ថាអីទេ យើងឈើពិតនោះ ។

ឈុនលី ៖ ហើយឈើចឹងគេឲ្យទៅពេទ្យដែរ?

វ៉ាត់ ៖ ឈើគេឲ្យទៅពេទ្យ ពេទ្យនៅប៉ោយសំរោងគេធ្វើពេទ្យនៅប៉ោយសំរោង ។

ឈុនលី ៖ ហើយកាលធ្វើការនៅនោះហត់ដែរអត់? ធ្វើការយ៉ាងម៉េចដែរទៅ ហូបចុកអី?

វ៉ាត់ ៖ ហូបចុកមានអីធម្មតា បបូរតើមិនអីទេ ។

ឈុនលី ៖ ធ្វើពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

វ៉ាត់ ៖ ម៉ោង១០ ១១គេឲ្យឡើងហូបបាយហើយ ។

ឈុនលី ៖ ពីព្រលឹមឡើងធ្វើការម៉ោងប៉ុន្មាន?

វ៉ាត់ ៖ ម៉ោង៦ ម៉ោង៧គេឲ្យទៅធ្វើការ ម៉ោង១០ ១១គេឲ្យទៅហូបបាយហើយ ។

ឈុនលី ៖ ចុះព្រលឹមឡើងអត់មានបាយទេអាយើងម៉ោង៦ម៉ោង៧ហ្នឹង?

វ៉ាត់ ៖ ទេ គេឲ្យយើងទ្រាប់ពោះដែរតើ ។

ឈុនលី ៖ គេមានបាយពេលព្រឹកឲ្យ?

វ៉ាត់ ៖ ចាស!

ឈុនលី ៖ គេមានបាយឬមានបបរ?

វ៉ាត់ ៖ ហូបបាយ មានអីយើងធ្វើការចឹងគេឲ្យហូបបាយតើ ។

ឈុនលី ៖ ច្រើនឬតិច?

វ៉ាត់ ៖ បាយមានអីច្រើនតើ យើងធ្វើការនៅទំនប់ចឹងច្រើនតើ ។

ឈុនលី ៖ ប្រហែលប៉ុណ្ណាទៅ?

វ៉ាត់ ៖ ល្មមតែម៉ាឆ្អែតៗ ហើយសម្លរមានអីចែកគ្នាម៉ាក្រុមដប់នាក់ទៅក៏ចែកគ្នាទៅ ម៉ាចានៗទៅម្នាក់ៗសម្លរ បើមិនឆ្អែតទេក៏យកទៀតទៅ ។

ឈុនលី ៖ ម៉ោង១០ឬ១១ឡើងពីធ្វើការ?

វ៉ាត់ ៖ ១១ឡើងទៅធ្វើការ ម៉ោង១ឡើងទៅធ្វើការទៀតទៅដឹកទៀតទៅ ។

ឈុនលី : ចុះល្ងាចឡើងម៉ោងប៉ុន្មានឈប់?

វ៉ាត់ : ជួនកាលទៅម៉ោង៣ម៉ោង៤ឡើងហើយ ។

ឈុនលី : រហ័សឡើងម៉េះ ម៉ោង៤ភ្លឺហ្នឹង?

វ៉ាត់ : ម៉ោង៤ល្ងាចណាស!

ឈុនលី : ចាស!តែវានៅភ្លឺហ្នឹង?

វ៉ាត់ : នៅភ្លឺមុជទឹកមុជអីទៅ ។

ឈុនលី : ចុះទំនេរធ្វើអីទៀត?

វ៉ាត់ : ទំនេរមានធ្វើអីបើថានេះយើងទៅជីកអីហូបទៅ ។

ឈុនលី : គេឲ្យដែរឯកជនហ្នឹង?

វ៉ាត់ : មានអីឲ្យយើងអីបានស៊ីខ្លះដែរវាយ៉ាប់តែយើងលើកទំនប់ហ្នឹងឯង ។

ឈុនលី : ហើយមានអ្នកឈឺច្រើនទេកាលនោះ?

វ៉ាត់ : ឈឺច្រើន បាក់កំលាំងច្រើនខ្លះក៏មកដេកពេទ្យទៅ ខ្លះក៏ស្លាប់ទៅ ។

ឈុនលី : មានស្លាប់ដែរ? ស្លាប់ច្រើនទេកាលអឹនៅនោះ?

វ៉ាត់ : ស្លាប់ខ្លះតែមិនសូវមានច្រើនទេ ។ អាខ្លះទុកបានក៏ជាទៅ អាខ្លះទុកមិនបានក៏ស្លាប់ទៅ ។

ឈុនលី : ហើយដូចយើងទៅធ្វើការចឹងស្នាក់នៅឯណាទៅ?

វ៉ាត់ : នៅខ្ទមនោះអូន!

ឈុនលី : គេធ្វើខ្ទមនៅជិតទំនប់ហ្នឹងហ្អី?

វ៉ាត់ : ហ្នឹងហើយធ្វើនៅជិតទំនប់ហ្នឹងជុំគ្នា គ្នា២០ ៣០នាក់ក៏នៅជុំគ្នា បីក្រុមក៏នៅជុំគ្នាទៅ ស្រុកគេនៅតាមស្រុកគេទៅ ស្រុកយើងនៅតាមស្រុកយើងទៅ ។

ឈុនលី : ចុះអឹនៅគ្នាប៉ុន្មាននាក់ទៅ?

វ៉ាត់ : ខ្ញុំនៅប៉ុន្មាននាក់ទេ ចែកគ្នាជាបីក្រុមទៅយើងស៊ីទៅ ។

ឈុនលី : ចែកជាបីក្រុមមិនដប់ៗ?

វ៉ាត់ : ដប់ៗ ។

ឈុនលី : ហើយគេដាំបាយឲ្យ?

វ៉ាត់ : ចា៎!គេមានចាត់ចុងភៅផ្សេងឲ្យដាំ ។

ឈុនលី : កាចទេចុងភៅ?

វ៉ាត់ : មានកាចអី មិនកាចទេ ។

ឈុនលី : ចុះពេលយើងធ្វើការចឹងអ្នកណាអ្នកដើរមើលការខុសត្រូវ?

វ៉ាត់ : គេអ្នកវាស់ដីហ្នឹងឯង គេអ្នកមើលខុសត្រូវ ។

ឈុនលី : ស្គាល់ទេ?

វ៉ាត់ : ខ្ញុំស្គាល់តែ ពូថង ទេគាត់ស្លាប់បាត់ហើយ ទាល់តែគេឲ្យពួកប្រធានៗត្រួតពិនិត្យវាស់ដីវាស់អី ។

ឈុនលី : កាចទេ ថងហ្នឹង?

វ៉ាត់ : ថា...គាត់មិនបាចទេស្រួលណាស់ ។

ឈុនលី : ចុះពេលដីកចឹងមានថ្នាក់លើគេមកមើលទេ?

វ៉ាត់ : ដូចមិនឃើញថ្នាក់លើអីទេឃើញតែគាត់អ្នកកាន់ក្តាប់ដើរមើលអីចឹងទៅមកៗ ។

ឈុនលី : មានតែអ្នករបៀបថាល្មមៗ?

វ៉ាត់ : ល្មមៗទេ ។

ឈុនលី : ដូចមេធំៗអីអត់មកទេ?

វ៉ាត់ : អត់មកទេ ។

ឈុនលី : ត្រឹមគណៈស្រុកអីមានទេ?

វ៉ាត់ : មិនដែលឃើញទេ ។

ឈុនលី : អ្នកណាគេគណៈស្រុកកាលនោះ?

វ៉ាត់ : គណៈស្រុកកាលនោះខ្ញុំមិនស្គាល់ទេ ច្រើនណាស់គណៈស្រុកមិនដឹងមួយណាទេ ។

ឈុនលី : ចុះអ៊ឹមានស្គាល់ យាយថែម ទេ?

វ៉ាត់ : យាយថែម...ថែម ខ្ញុំមិនស្គាល់មិនដឹង ថែម មួយណាទេ ។

ឈុនលី : យាយថែម គាត់នៅកាន់ហ្នឹងធំដែរ ដូចជាគាត់កាន់ខាងគណៈស្រុក ។

វ៉ាត់ : ថែម អ៊ឹមិនស្គាល់គេទេ ។

ឈុនលី : ចុះអ៊ឹថា រី ហ្នឹងឋានៈគាត់ជាអីគេ?

វ៉ាត់ : គាត់កាន់ខាងប្រធានសហករណ៍ បើកអង្ករបើកត្រីសាច់អីណាស ។

ឈុនលី : ចុះមេបស់រីទៀតអ្នកណាគេ?

វ៉ាត់ : រី ហ្នឹងនិរតីហើយដូចមិនឃើញមេទេ ឃើញតែ រី ហ្នឹងឯង ។

ឈុនលី : កាចទេ រី ហ្នឹង?

ភ៉ាត់ : មិនបានកាចទេគាត់ល្អណាស់ បើនិយាយទៅកាចដោយមនុស្សដែរមនុស្សណាឲ្យកាចមនុស្សណាមិនឲ្យកាចមិនកាចទេ ។

ឈុនលី : តែអីដែលជួបមនុស្សដែលកាចៗទេ អ្នកគ្រប់គ្រង?

ភ៉ាត់ : ដូចមិនមានអ្នកណាកាចផងធ្វើចេះតែត្រូវទៅ ប្រឹងធ្វើការទៅ ។ ដឹងតែធ្វើការវាស់ល្ងាចដូចតែគ្នាទៅ ។

ឈុនលី : ហើយកាលនោះដកក្នុងខែណាដែលចាប់ផ្ដើមដក? មានភ្លៀងធ្លាក់ដែរ?

ភ៉ាត់ : មានភ្លៀងខ្លះដែរឯង នាំគ្នាទៅជ្រកតែនឹងខ្ទម ជួនកាលដេកមិនសូវលក់ផងចុះបើភ្លៀងវាស់តែព្រឹក ។

ឈុនលី : ចឹងពេលភ្លៀងយើងទៅសំរាក យើងអត់ទៅធ្វើអីទៀតទេ?

ភ៉ាត់ : ព្រឹកឡើងភ្លឺបើរាំងទៅធ្វើការទៀត បើភ្លៀងនៅសិន ផ្អាកសិន យើងរែកម៉េចកើតសុទ្ធតែទឹក ។ អាខ្លះទៅបាចទឹកបានក៏រែកទៅ រែកអាណាដែលស្ងួតទៅ អាណាដែលនេះបន្ទូរចេញទៅ ។

ឈុនលី : ចឹងកាលនោះការងារដែលគេចែកឲ្យអីធ្វើចប់ដែរ? ពីរម៉ែត្រ ម៉ាម៉ែត្រកន្លះអី?

ភ៉ាត់ : ធ្វើហើយ ជួនកាលដែលកំលាំងយើងបានរួចទៅ តែម៉ោងពីរដណ្ដប់ បីដណ្ដប់ម៉ោងមួយអីរួច ម៉ោងពីររួច ។

ឈុនលី : គេចែកថែមទៀតហ្អីកាលណាធ្វើហើយ ។

ភ៉ាត់ : តែកាលណាយើងធ្វើហើយថ្ងៃពេក គេបន្ថែមឲ្យយើងកន្លះម៉ែត្រទៀត ដល់តែមើលទៅខ្សោយខ្លាំងតែម៉ាម៉ែត្រ កន្លះម៉ែត្រក៏មិនរួច កំលាំងកាន់តែអន់កាន់តែខ្សោយ ។ មុនដឹបួងមានអីចំនាប់ចំនួនតើដល់តែយូរទៅ...

ឈុនលី : អីថាមេដែលមើលការខុសត្រូវអីហ្នឹងឈ្មោះអីគេនៅកន្លែងណុង ដូចថាយើងឈឺយើងអីសុំច្បាប់គេចឹងណាស?

ភ៉ាត់ : កូនយាយភ៉ាត នេះឯងឈ្មោះ សៀន ឲ្យនៅកាន់ក្ដាប់ខាងកូនខ្វែង ។

ឈុនលី : អត់ទេ អាកាលនៅត្រពាំងថ្មណាស?

ភ៉ាត់ : ហួស!កាលនោះងាប់អស់បាត់ទៅហើយមិនដឹងនោះភ្លេចឈ្មោះអស់ហើយ ។

ឈុនលី : ឈ្មោះអីខ្លះទៅ?

ភ៉ាត់ : ឈ្មោះតាស្ដីទេខ្ញុំភ្លេចដែរនោះ ។

ឈុនលី : តែអីនិយាយមិញហ្នឹងនៅត្រពាំងថ្មតើហ្អីមិនមែននៅកូនខ្វែងទេ?

វ៉ាត់ : កូនខ្មែរនោះឈ្មោះ សៀន កូនយាយវ៉ាតដែលនៅក្តាប់នៅកូនខ្មែរ ។

ឈុនលី : អ៊ីថាទៅវែកទំនប់ហ្នឹងពីរកន្លែង?

វ៉ាត់ : ចា៎!ពីរកន្លែង ។

ឈុនលី : ទីមួយគឺនៅស្ពានរាប ទីពីរគឺនៅកូនខ្មែរ?

វ៉ាត់ : ចាស!

ឈុនលី : ចាស អ៊ីចឹងខ្ញុំសុំសួរអ៊ីទាក់ទងនឹងនៅស្ពានរាបកន្លែងត្រពាំងថ្មហ្នឹងណាស អ៊ីថាអាហ្នឹងហ្អី ដែលលើកឡើងខ្ពស់ហើយគេចែកឲ្យពីរម៉ែត្រ?

វ៉ាត់ : លើកពីរម៉ែត្រ ។

ឈុនលី : ដែលអ៊ីថាឈឺមកផ្ទះវិញនោះណាសអាហ្នឹងធ្វើនៅស្ពានរាបទេ?

វ៉ាត់ : ស្ពានរាប ។

ឈុនលី : ធ្វើបានប្រហែលពីរខែត្រលប់មកវិញ?

វ៉ាត់ : ចាស!ឈឺ ។

ឈុនលី : កាលនោះហ្អីមានអ្នកស្លាប់ដោយសារឈឺ?

វ៉ាត់ : មាន មានគេឈឺស្លាប់ដែរតើអូន ។

ឈុនលី : មានអ្នកស្លាប់ច្រើនទេ?

វ៉ាត់ : មិនសូវមានទេ ។

ឈុនលី : ហើយមានអ្នកស្លាប់នៅនឹងកន្លែងហ្នឹងទេ?

វ៉ាត់ : មានឈឺស្លាប់ គ្រុនឈឺ ។

ឈុនលី : ដល់ពេលទៅជីកស្លាប់នៅកន្លែងនោះណាស មានដែរទេ?

វ៉ាត់ : មានខ្លះដែរណាស ។

ឈុនលី : ដល់ពេលអ៊ំឃើញចិនភ័យដែរ?

វ៉ាត់ : ឃើញចិនភ័យដែរហើយ បេះតែខ្លាច ។

ឈុនលី : ខ្លាចទេអ៊ំទៅជីកទៅអីចឹង?

វ៉ាត់ : ខ្លាចដែរ ឈឺល្មមៗត្រូវតែទៅ តែមិនទៅគេរករឿងទៀតណាស ហើយទៅទាល់តែមាន កំលាំងទៅបានណាសដល់តែទៅមិនបាន ឈឺក៏...

ឈុនលី : អ៊ីចឹងពិបាកអីខ្លះទៅអ៊ំទៅជីកហ្នឹង?

ភាត់ : ពិបាក ហ៊ឹស!ចុះទៅលើកដីមានស្រាលឯណាអូន ធ្ងន់ វែកឡើងនោះមិនធម្មតាអីណា កំលាំងកាន់តែខ្សោយទៅៗមិននេះឯណាវែកដីម្នាងម៉ាបង្គីៗថ្ងៃៗហើយស៊ី អារឿងស៊ី គ្រប់គ្រាន់ម្ហូបម្ហារអី តែយ៉ាប់កំលាំងឈឺ ។

ឈុនលី : តែឈឺមានពេទ្យ?

ភាត់ : មានពេទ្យគេចុះជាប់ដែរតើ ពេទ្យនៅតាមទំនប់ ។

ឈុនលី : នៅកន្លែងអាងហ្នឹង?

ភាត់ : ចាស!នៅជិតជំរុំដែលពួកខ្ញុំដេក អ្នកណាឈឺគ្រូនអី ។

ឈុនលី : អាហ្នឹងគេចែកជាក្រុមទេតើហ្អី ដូចម៉ាក្រុមប៉ុន្មាននាក់នៅជិតគ្នាអីចឹងហ្អី?

ភាត់ : យើងក្រុមចឹងជីកទាំងអស់តែគ្នា ដង្គែតែគ្នា ។

ឈុនលី : តែក្រុមប៉ុន្មាននាក់ក្រុម?

ភាត់ : ដប់នាក់ៗប្រហែលតែគ្នា ដប់នាក់ប្រធានក្រុមមួយៗ ។

ឈុនលី : ចុះប្រធានក្រុមអ៊ំឈ្មោះអីគេ?

ភាត់ : ប្រធានក្រុមឈ្មោះ...មិនដឹងឈ្មោះអីទេភ្លេចអស់ហើយប្រធានក្រុមខ្ញុំនោះ ។

ឈុនលី : ហើយនៅបានពីរខែត្រលប់មកវិញ?

ភាត់ : ត្រលប់មកវិញ ។

ឈុនលី : ត្រលប់មក មកនៅឯណា?

ភាត់ : ត្រលប់មកហើយអត់មានទៅណាទេ ប្រហែលម៉ាខែទៀតបានគេឲ្យទៅកូនខ្វែង ទៅកូនខ្វែងបានប្រហែលម៉ាអាទិត្យត្រលប់មកវិញ ខ្ញុំវែកទឹកនៅនឹងកូនខ្វែងនេះ បងប្អូនជីដូនមួយអីទៅវែក ។

ឈុនលី : ចុះពេលប្រលប់មកវិញមកនៅភូមិវិញហ្អី នៅភូមិជើងវត្ត?

ភាត់ : ដល់ពេលមកវិញគេឲ្យទៅនៅប៉ោតសំរោង លើកទំនប់នៅចៅយសំរោងទៀត នៅស្រែះ នេះណាស លើកនៅស្រែះទៀត ។

ឈុនលី : មកពីស្ពានរាបហើយទៅស្រែះទៀត?

ភាត់ : អត់ទេ មកពីកូនខ្វែង ។

ឈុនលី : ចុះបើចេញពីស្ពានរាបហ្នឹងទៅណា?

ភាត់ : ចេញពីស្ពានរាបមានស្រុកគេលើកដងដីងព្រោះអីខ្ញុំមកលើកនៅនេះ ។

ឈុនលី : ចឹងបានន័យថាអ៊ំទៅធ្វើការហ្នឹងទៅកូនខ្វែងទេចឹង?

ភ៉ាត់ : ទៅកូនខ្វែងបានម៉ោអាទិត្យអត់ទឹកបានគេឲ្យទៅធ្វើនៅប៉ោយសំរោងទៀត ។

ឈុនលី : ចុះដំបូងអីចឹងថាទៅស្ពានរាប?

ភ៉ាត់ : ចាស!

ឈុនលី : ដល់ពេលឈឺត្រលប់មកវិញ?

ភ៉ាត់ : ត្រលប់មកវិញ ។

ឈុនលី : ត្រលប់មកវិញមកនៅឯណា?

ភ៉ាត់ : នៅនឹងប៉ោយសំរោងនេះហើយអូន ។

ឈុនលី : ត្រលប់មកវិញបានទៅប៉ោយសំរោង?

ភ៉ាត់ : ប៉ោយសំរោងយើងនេះ ។

ឈុនលី : ហើយពេលណាបានទៅកូនខ្វែង?

ភ៉ាត់ : អាហ្នឹងពេលទៅស្ពានរាបបានម៉ាខែគេឲ្យទៅកូនខ្វែង ត្រលប់ពីកូនខ្វែងវិញបានម៉ាអាទិត្យ ។

ឈុនលី : មកម៉ាខែហ្នឹងនៅឯណា?

ភ៉ាត់ : នៅជើងវត្តនេះឯង ។

ឈុនលី : នៅផ្ទះ?

ភ៉ាត់ : ចា៎! នៅផ្ទះដែលឈឺនោះ ។

ឈុនលី : ទៅពេទ្យទៅអីហ្អី?

ភ៉ាត់ : ចាស! ឲ្យពេទ្យគេមើល ។

ឈុនលី : កាលនោះឈឺអីគេ?

ភ៉ាត់ : ខ្ញុំកាលនោះវាញាក់ ។

ឈុនលី : ចាញ់ហ្អី?

ភ៉ាត់ : ហ្នឹងហើយបែបចាញ់ ។

ឈុនលី : ចុះអ្នកផ្សេងទៀតចាញ់ច្រើនទេ?

ភ៉ាត់ : ចាញ់ច្រើនដែរតែគេឆាប់បាត់ បើខ្ញុំក្របាត់ ។ ពេទ្យយើងសព្វថ្ងៃវត្តនេះឯង ។

ឈុនលី : ទៅកូនខ្វែងហ្នឹងទៅជីកដីទៀតហើយ?

ភ៉ាត់ : ទៅជីកដីទៀតណាស ខ្ញុំលើកបានប៉ុន្មានថ្ងៃក៏ប្រធានក្រុមថាបើលើកដីមិនរួចទេ លើកទឹកទៅ ប្អូនជីដូនមួយខ្ញុំ វែកជាមួយគ្នាហ្នឹងឯង វែកដាក់បំពង់ ។

ឈុនលី : វែកទឹកពីណាទៅណា ធ្វើអី?

រ៉ាត់ : វែកឲ្យគេដឹកណាស អត់មានទឹកដឹកទេណាសអូនកន្លែងនោះ ។

ឈុនលី : ចុះអាកាលនៅស្ពានរាបមានទឹកដឹក?

រ៉ាត់ : ដឹកទឹកអីគេអាហ្នឹង?

ឈុនលី : អាហ្នឹងទឹកគេដឹកមកឲ្យយើងដឹកទឹកគេដឹកមក ឡានគេដឹកមកឲ្យយើងដឹក ។ ចុះនៅកូនខ្វែងធំទេ?

រ៉ាត់ : កូនខ្វែងតូចមិនមែនធំស្ពានរាបទេ ។

ឈុនលី : ជាភូមិហ្អី? កូនខ្វែងហ្អី?

រ៉ាត់ : គេហៅភូមិកូនខ្វែងនៅទីនោះតមមាត់ណាស់ណាអូនអត់ហ៊ាននិយាយអីទេ ។

ឈុនលី : នៅក្នុងឃុំអីគេ?

រ៉ាត់ : មិនដឹងជាឃុំអីទេ ។

ឈុនលី : នៅស្រុកព្រះនេត្រព្រះដែរ?

រ៉ាត់ : ទេ អត់នៅស្រុកព្រះនេត្រព្រះទេ ។

ឈុនលី : នៅឯណាទៅ?

រ៉ាត់ : ទេ អត់ដឹងនៅឯណាទេ គេហៅឃុំអីគេទេ ។

ឈុនលី : ឆ្ងាយពីនេះទេកូនខ្វែង?

រ៉ាត់ : ឆ្ងាយណាស់ ឆ្ងាយមែនទែនទៅណាស ។

ឈុនលី : អត់ដឹងស្រុកទេចឹង?

រ៉ាត់ : អត់ដឹងស្រុកទេ ហើយដល់តែខ្ញុំលើកបានម៉ាអាទិត្យអត់មានទឹកមុជក៏គេឲ្យមកវិញមកមុជទឹកនៅព្រៃមាន់ កន្ទុយនៅព្រៃមាន់ ក្បាលនៅទទឹងថ្ងៃខាងកើតនោះថាឲ្យចូលភូមិ មានចូលភូមិឯណាឲ្យហួសទៅបៅយសំរោងទៀតណោះ ។

ឈុនលី : ចឹងទៅកូនខ្វែងបានតែម៉ាអាទិត្យទេ?

រ៉ាត់ : ចាស! បានតែម៉ាអាទិត្យទេ ចុះបើអត់មានទឹកមុជ ។

ឈុនលី : ចឹងអឺសុំគេមកបានដែរ?

រ៉ាត់ : មកទាំងអស់គ្នា ។

ឈុនលី : ចឹងមិនបានន័យថាឈប់ដឹកហើយ?

រ៉ាត់ : ឈប់ដឹក ។

ឈុនលី ៖ ម៉េចបានដាឈប់ដឹក?

វ៉ាត់ ៖ អត់មានទឹកមុជទឹកអីទេដឹងបានគេឲ្យមក ។

ឈុនលី ៖ ចឹងការងារមិនដាក់ចោលហើយចឹង? ដឹកហើយដាក់ចោល?

វ៉ាត់ ៖ ចោលហើយម៉ាអាទិត្យគេឲ្យមកវិញកន្ទុយពីព្រៃមាន់ ក្បាលមកដល់ទទឹងថ្ងៃ ។ ស្ពានតែឲ្យចូមភូមិដើងវត្ត មានឲ្យចូលភូមិឯណាឲ្យទៅដល់ប៉ោយសំរោងទៀត ហើយខ្ញុំនេះខ្ញុំឈឺកអត់បានលើក ។

ឈុនលី ៖ អីចឹងឥឡូវនៅកន្លែងកូនខ្វែងមានអាងមានអីដែរ?

វ៉ាត់ ៖ សព្វថ្ងៃមិនដឹងមានអាងដែរអត់ខ្ញុំមិនដឹងដែរបើម៉ាអាទិត្យមកវិញ ។

ឈុនលី ៖ គ្នាប៉ុន្មាននាក់ទៅ?

វ៉ាត់ ៖ គ្នាច្រើនឡើងប៉ុន្មានសន្តាត់ ។

ឈុនលី ៖ ប្រហែលប៉ុន្មានទៅ?

វ៉ាត់ ៖ ប៉ុន្មានឃុំប៉ុន្មានអីទេ ស្រុកគេជងស្រុកគេច្រើនណាស់រ ។

ឈុនលី ៖ តែតិចជាងត្រពាំងថ្មទេ?

វ៉ាត់ ៖ មនុស្សតិចជាង អានេះគេនៅតាមភូមិនៅតាមស្រុកណាស ។

ឈុនលី ៖ ហើយហូបចុកម៉េចទៅ?

វ៉ាត់ ៖ ទៅម៉ាអាទិត្យគេឲ្យមកវិញខ្ញុំថាតែគេឲ្យមកភូមិ គេឲ្យទៅប៉ោយសំរោងទៀតទៅលើកទំនប់នៅស្រែះ ។

ឈុនលី ៖ ប៉ោយសំរោងហ្នឹងភូមិ?

វ៉ាត់ ៖ ភូមិប៉ោយសំរោង ។

ឈុនលី ៖ ហើយទៅលើកទំនប់នៅស្រែះ?

វ៉ាត់ ៖ ចាស! ទៅលើកទំនប់នៅស្រែះកំបោរទៀត ទំនប់កំបោរយើងមិនសូវខ្ពស់ប៉ុន្មានទេ ទាបជាង ។ ហ្អួស! ខ្វាត់ខ្វែងណាស់អូនអើយ ចុះបើលើកមិនដែលគិតថាសម័យណាៗកាន់កាប់ភ្លេចអស់ ភ្លេចភ្លាំងអស់ ។

ឈុនលី ៖ ចុះដល់ពេលក្រោយមក ពេលទៅធ្វើការច្រើនកន្លែងចឹងអ៊ីមានដឹងទេថានៅស្ពានរាប នៅត្រពាំងថ្មហ្នឹងនៅតែធ្វើរហូតទេ?

វ៉ាត់ ៖ នៅតែធ្វើចឹង ។

ឈុនលី ៖ ពេលណាបានឈប់?

វ៉ាត់ : ដល់ពេលវៀតណាមចូលបានឈប់ ។

ឈុនលី : ចុះកាលវៀតណាមចូលហ្នឹងអ៊ីនៅឯណា?

វ៉ាត់ : យក្សណាមចូលខ្ញុំនៅឯណោះ ដើរវត្ត ។

ឈុនលី : ត្រលប់មកដើរវត្តទៀតហើយ?

វ៉ាត់ : នៅតែដើរវត្តរហូតតើលើកតែទំនប់ ។

ឈុនលី : ចុះទៅធ្វើការនៅឯណានោះ?

វ៉ាត់ : ចាំមើលណាស ទៅស្ពានរាបបានពីរខែទៅឯណោះទៅកូនខ្វែង ត្រលប់មកពីកូនខ្វែងបាន
តែម៉ាអាទិត្យទៅប៉ោយសំរោងទៀតណោះអូន ។

ឈុនលី : អាហ្នឹងខ្ទង់ឆ្នាំណា?

វ៉ាត់ : មិនដឹងឆ្នាំណាទេអ៊ីក៏មិនដឹងដែរហ្នឹងណាស ដល់បេះតែគេឲ្យទៅៗមិនដឹងគិតថាយ៉ាងម៉េច
គេថាឲ្យលើកក៏លើកទៅ ខ្ញុំមកពីនោះឈឺកលេបថ្នាំក៏បាត់ទៅ ។

ឈុនលី : ចឹងបានន័យថាក្នុងរបបហ្នឹងអ៊ីជីកតែទំនប់រហូត?

វ៉ាត់ : ជីកទំនប់រហូតលើកលែងតែឈឺហ្នឹងឯង តែឈឺឈប់ ។

ឈុនលី : គេអត់ឲ្យធ្វើការអីផ្សេងទៀតទេ?

វ៉ាត់ : អត់ទេ ។

ឈុនលី : ទៅដល់នោះជីកម្នាក់ឯងជីកប៉ុន្មានដែរ ។

វ៉ាត់ : ទំនប់នេះអ៊ីអត់បានជីកទេព្រោះអ៊ីមកពីកូនខ្វែងអ៊ីឈឺស្វា ។

ឈុនលី : ចឹងអ៊ីគេឲ្យធ្វើអីចោះ?

វ៉ាត់ : ឈឺ ខ្ញុំក៏មកពេទ្យ មកពេទ្យក៏មិនបានមកវិញ ។

ឈុនលី : មកពេទ្យហ្នឹងយើងព្យាបាលតើហ្អី?

វ៉ាត់ : មកព្យាបាលហ្នឹងហើយ ។

ឈុនលី : ហើយព្យាបាលរយៈពេលប៉ុន្មានទៅ?

វ៉ាត់ : យូរគ្រាន់ដែរប្រហែលកន្លះខែ ។

ឈុនលី : ចុះចេញពីពេទ្យទៅណាទៀត?

វ៉ាត់ : ចេញពីពេទ្យនៅផ្ទះ ។

ឈុនលី : នៅផ្ទះអត់ធ្វើអីទៀតទ?

វ៉ាត់ : ធ្វើការ បើយើងធ្វើបានក៏ធ្វើទៅបើមិនបានធ្វើជាមួយចាស់ៗទៅ ។

ឈុនលី ៖ ធ្វើអីគេទៅ?

វ៉ាត់ ៖ ជីរះស្មៅ ដាំដំឡូងមី អំពៅអីទៅណាសឲ្យតែយើងធ្វើ ។

ឈុនលី ៖ ចុះនៅដាំអាហ្នឹងយូរដែរអត់ទំរាំតែផុតរបប?

វ៉ាត់ ៖ យូរគ្រាន់ដែរ ដល់តែយើងដាទៅៗទៀត ស្គមនៅតែស្បែកដណ្តប់ឆ្អឹង ។

ឈុនលី ៖ ចឹងពេលចេញពីកូនខ្មែងទៅបៅយសំរោងហ្នឹងអឹងអត់បានធ្វើអីទេ?

វ៉ាត់ ៖ អាល័យតែឈឺស្មា ។

ឈុនលី ៖ ឈឺស្មាបកមកវិញធ្វើការនៅផ្ទះ?

វ៉ាត់ ៖ ធ្វើការនៅផ្ទះជីរះស្មៅជាមួយចាស់ៗ កាលនោះឯងវាស្គមស្គាំងពេក ។

ឈុនលី ៖ ចុះដូចអឹចេះតែឈឺចឹងគេអត់ស្តីឲ្យទេ?

វ៉ាត់ ៖ ទេ មិនស្តីឲ្យទេឲ្យតែឈឺពិត បើឈឺមិនពិតគេស្តីឲ្យ បើយើងឈឺមល្មមគេថាយើង គេប្រណែនយើងហើយ តែបើយើងឈឺដេកកន្ទេលមានអ្នកណាគេថាឲ្យយើងទេ ។

ឈុនលី ៖ ចុះពេលអឹឈឺចឹងគេឲ្យរបបដូចគេដូចឯងដែរអត់?

វ៉ាត់ ៖ មានអីបើយើងឈឺពិតចឹងបានរបបអត់អីទេ ។

ឈុនលី ៖ ហូបអីគេរបប?

វ៉ាត់ ៖ មានតែសម្លអីហ្នឹងហើយ ។

ឈុនលី ៖ អត់មានបបរអីទេចឹង?

វ៉ាត់ ៖ បបរក៏បាន បើមិននេះទេយើងទៅសុំអង្ករគេមកបបរទៅគេឲ្យ ។

ឈុនលី ៖ ចុះអឹឈឺចឹងគេឲ្យហូបបាយដែរ? ចឹងនៅនេះគេអត់ហូបបបរទេចឹង?

វ៉ាត់ ៖ បាយពេលយើងចេញធ្វើការយើងហូបបាយ តែពេលយើងឈឺគេឲ្យហូបបបរ យើងសុំអង្ករគេមកបបហូប ។

ឈុនលី ៖ ចឹងអត់ទៅហូបជាមួយគេទេសុំអង្ករគេមកបបរ?

វ៉ាត់ ៖ ចាស! ចុះបើគេអត់បបរផងគេហូបតែបាយ ។ ចុងឆ្នាំ៧៥ ៧៦ ៧៨បបរម្នាក់ម៉ាវែក ។

ឈុនលី ៖ ចឹងដល់ពេលអឹធ្វើការនៅផ្ទះ យូរទៀតទេបានវៀតណាមចូល?

វ៉ាត់ ៖ យូរដែរបានវៀតណាមចូល ។

ឈុនលី ៖ ប្រហែលប៉ុន្មានឆ្នាំទៅ?

វ៉ាត់ ៖ ទេ មិនចាំឆ្នាំទេ ។

ឈុនលី ៖ ពេលវៀតណាមចូលមកហ្នឹងយ៉ាងម៉េចខ្លះទៅអឹ?

រ៉ាត់ : វៀតណាមចូលមកហ្នឹងក៏នៅតែខ្លាចវាដែរ ចុះកាំភ្លើងកាន់ប្រផេងប្រផាំងនៅខែខ្លាចវាដែរ មិនទាន់ទុកចិត្តគេក៏ចេះតែខ្លាច ។ នៅតែវាលណាស មិនដែលនៅក្នុងភូមិផងហ្នឹង ។

ឈុនលី : ចូលមកបាញ់គ្នាម៉ែង?

រ៉ាត់ : អត់បាញ់ទេគ្រាន់តែវាកាន់កាំភ្លើងទៅមកៗ បើនៅតែវាលដល់យូរៗ ទៅបានហ៊ានចូល ។

ឈុនលី : ចុះពេលនោះខ្មែរក្រហមនៅហ្នឹងដែរ?

រ៉ាត់ : អត់ហ៊ាននៅទេ ចុះម៉េចហ៊ាននៅបើវៀតណាមនៅពេញតែហ្នឹងដែលហ៊ាននៅអីវា ។

ឈុនលី : ប៉ុន្មានថ្ងៃដែលចូលមក?

រ៉ាត់ : ចូលមកបានយូរគ្រាន់ដែរហើយចូលតាមភូមិ ថាហកវៀតណាមចូលហើយ ។ កាលនោះខ្លាចវៀតណាមទៀតនោះ ។ ខ្លាចណាស់ឃើញកាំភ្លើងប្រផេងប្រផាំងខ្លាចអត់មានអ្នកណាហ៊ាននៅក្នុងភូមិចេញតែវាល ដេកទៃវាល ។ នាំគ្នាចូលមកសន្សឹមៗខ្លាចអីចូលមកតែនៅតែខ្លាច ឃើញប្រផេងប្រផាំងចេះតែខ្លាចទៅ ។

ឈុនលី : គេអត់ធ្វើអីយើងទេវៀតណាម?

រ៉ាត់ : ចាស!គេអត់ថាអីយើងទេ បើគេរំដោះបាន ។

ឈុនលី : ចុះពួកអាពតនាំគ្នារត់ទៅណា?

រ៉ាត់ : រត់ទៅនោះឯង រត់ទៅខាងជើង ។

ឈុនលី : ខាងជើងហ្នឹងខាងណាវិញ?

រ៉ាត់ : រត់ឲ្យផុតពីពួករំដោះទៅ ។

ឈុនលី : អ៊ីដែលឃើញគេចាប់មនុស្សយកទៅណាទៅណីដែរ?

រ៉ាត់ : ចំការដូងម៉ាជួរដក់ពរនេះឯងគេយកទៅទាំងខ្សែៗ ។

ឈុនលី : យកទៅណា?

រ៉ាត់ : យកទៅវ៉ៃចោល ។

ឈុនលី : ខុសម៉េចទៅអ៊ីចាំទេ បើចាំសុំជួយរៀបរាប់ផង?

រ៉ាត់ : តែមកម៉ាជំនាន់ៗ ចាប់អានេះចាប់អានោះយកទៅវ៉ៃចោលដូច តាថងតាអី ។

ឈុនលី : គេចាប់តែមេៗតើហ្អី?

រ៉ាត់ : តាថង ប្តីយាយអ៊ុននៅជ្រោយសំរោង ។

ឈុនលី : ម៉េចបានចាប់គាត់អីចឹង?

រ៉ាត់ : ចាប់...

ឈុនលី : គេចោទគាត់ថាអីបានគេចាប់ខ្លួន?

វ៉ាត់ : មិនដឹងថាគេចោទថាអីបើខ្ញុំមកពីធ្វើការទៅឃើញតែគេចងនៅនឹងជង្រុក មុខឡើងក្រពុលអស់ ។

ឈុនលី : អត់មានអ្នកណាដឹងទេថាហេតុអីបានចាប់?

វ៉ាត់ : មិនដឹងហេតុអីទេ ហត់តែមកឃើញ ។

ឈុនលី : អត់ឆ្ងល់ទេចឹង?

វ៉ាត់ : មិនដឹងរឿងអីទេអូន ដូចតាគោតាអី ។

ឈុនលី : ហើយអារឿងចំការដូងហ្នឹងយ៉ាងម៉េចទៅ?

វ៉ាត់ : ចំការដូងហ្នឹងកន្លែងគេសំលាប់ ។

ឈុនលី : អឺឃើញតែគេចាប់ទៅទេតើហ្អី?

វ៉ាត់ : ចាស! ឃើញតែគេចាប់ទៅ ។

ឈុនលី : ទាំងស្រីទាំងប្រុសហ្អី?

វ៉ាត់ : ទៅស្រីក៏ស្រី ប្រុសក៏ប្រុស ។

ឈុនលី : ទៅទាំងខ្មែរចឹងទៅ?

វ៉ាត់ : ទាំងខ្មែរៗចឹង ។

ឈុនលី : យកទៅដាក់ត្រឹមណា?

វ៉ាត់ : នៅយើងច្រកខាងលិចដក់ពរនេះឯង ។

ឈុនលី : យកទៅសំលាប់នៅទីនោះ?

វ៉ាត់ : នៅនោះឯង ។

ឈុនលី : សំលាប់ម៉េចទៅ អឺគ្រាន់តែឃើញគេដឹកតើហ្អី?

វ៉ាត់ : គ្រាន់តែឃើញគេដឹកទេ មិនដែលហ៊ានតាមដានគេទេអូនអើយ ។

ឈុនលី : ទាហ៊ានហ្អី ឈ្លប?

វ៉ាត់ : ឈ្លបអីហ្នឹង ។

ឈុនលី : ហើយដូចយើងអ្នកស្រុកឃើញចឹងម៉េចទៅ?

វ៉ាត់ : យើងដែលទៅហ៊ានកំរើកហ្អី ព្ទុតែមាត់ស្រែកវេកវ៉ូកៗដែលឈ្នះគេហ្អាស មិនឈ្នះគេទេ ដឹកទៅយើងនេះមិនហ៊ានអើតក្បាលទេ ។ មើល តាគោ គាត់នៅកាប់អុសខ្លោកៗស្រាប់តែមានឈ្មោះមិនដឹងរឿងអីស្រាប់តែយកទៅបាត់ មិនដឹងរឿងអីៗបើគេចាប់ទៅបាត់ ។

បើអ្នកណាមានឈ្មោះ ទៅវាលចាំផ្ដាំឲ្យតែមកត្រូវឈ្មោះគេចាប់យកទៅ ។

ឈុនលី : ចឹងយើងអ្នកនៅឃើញចឹងភ័យទេ?

វ៉ាត់ : ជីមិនភ័យហ្អសមិនដឹងឈ្មោះណាៗភ័យហើយ ។

ឈុនលី : គេសុទ្ធតែមានបញ្ជីមក?

វ៉ាត់ : ចាស!សុទ្ធតែមានបញ្ជីមកពីលើ ។

ឈុនលី : អ៊ឹយឃើញគេកាន់ហ្អី?

វ៉ាត់ : ចុះបើសរសេរឈ្មោះនោះឈ្មោះនោះហើយតែគេមកពីថ្នាក់លើគេមានឈ្មោះនេះឈ្មោះ នោះហើយចាប់ពឹបយកទៅបាត់ ។

ឈុនលី : ហើយអត់មានអ្នកណាដឹងថាខុសអីទេក្រោយមកទៀតនោះ?

វ៉ាត់ : មិនដឹងថាខុសអីទេ កូនឯងសួរអ៊ឹមិនដឹងថាខុសអីទេ ។

ឈុនលី : ភាគច្រើនប្រជាជនឬក៏ថ្នាក់មេៗ?

វ៉ាត់ : មេៗ ។

ឈុនលី : ចាប់តែមេៗទេ ប្រហែលប៉ុន្មាននាក់ទៅ?

វ៉ាត់ : កាលខ្ញុំនេះមាន តាថង តាគោនេះឯង ។

ឈុនលី : ដែលអ៊ឹឃើញទាំងខ្សែៗប្រហែលប៉ុន្មាននាក់?

វ៉ាត់ : អូនអឹយ!តែគេចាប់គេមិនចាប់តែភូមិយើងទេមានភូមិគេទៀតនោះ ។

ឈុនលី : តែអ៊ឹយើបណ្ដើរហ្នឹងបណ្ដើរយ៉ាងម៉េច?

វ៉ាត់ : ឃើញតែគេមកចាប់ហ្នឹង ឃើញ តាថង គេចាប់ដាក់នៅក្នុងជង្រុកដល់ខ្ញុំទៅបើករបបទៅ ឃើញ ។

ឈុនលី : អ៊ឹកំពុងធ្វើអីគេកាលនោះ?

វ៉ាត់ : ខ្ញុំមកពីធ្វើការស្ទូងដកនេះឯងនៅឯវាលនោះឯង មកវិញឃើញគាត់ហើមមុខស្អុល ខ្ញុំថា ស្រេចហើយ ។ នេះឯងគាត់នេះជំនាន់គាត់ ។

ពួយ : អស់កូនមួយហើយខ្ញុំកូនពីរទៅចល័តគេមិនឲ្យមកស្រុកមកស្រែវិញទេ ។

វ៉ាត់ : គេមិនឲ្យទៅ ឃើញមុខកូនទេតែបងមិនស្គាល់ប្អូន កូនមិនស្គាល់ម៉ែទេ ។

ពួយ : គេថាមិនមែនកូនឯងទេ កូនអង្គការ ខ្ញុំផាប់កូនអស់ពីរក្រមមុំទៅចល័តនៅអាងត្រពាំងថ្ម ។

ឈុនលី : អ៊ឹទៅធ្វើការនៅឯណា?

ពួយ : ខ្ញុំចល័តគ្រប់កន្លែង ។

វ៉ាត់ : គាត់នេះឯងសម័យនោះ ។

ឈុនលី : ធ្វើការនៅត្រពាំងថ្មដែរអត់?

ពួយ : ទេ កូនទៅ ខ្ញុំនៅតាមភ្នំនេះ តាមគោកក្រោលតាមអីណាកំបោរអីណា ភ្នំកំបោរភ្នំលាភ អីណាចល័ត នៅខាងស្ទួងដក ។

វ៉ាត់ : ស្ទួងដកៗទំបន់ក៏ទំនប់ ប្រឡាយនេះឯងគេមិនដែលឲ្យឈប់ ។

ពួយ : ពីដើមមិញឲ្យពីរម៉ែត្រគីប យូរទៅឯងប្ដេជ្ញាទៅឲ្យបីម៉ែត្រគីប ហើយធ្វើមិនរួចមិនឲ្យ បាយស៊ី មិនឲ្យឡើង ។ ខ្ញុំនេះហើយមិនដែលបាននៅស្រុក ។

ឈុនលី : អ៊ឹជីកដែរពីរម៉ែត្របីម៉ែត្រហ្នឹង?

ពួយ : ចាស ជីក ។

ឈុនលី : ជីកនៅឯណា?

ពួយ : នៅតាមកំបោរ ភ្នំស្រេះ ហួស!ភ្នំស្រេះកំបោរ ទៅអីណោះគោកក្រោមប្រព័ន្ធភ្លឺលើក តំនប់ប្រឡាយដែរ ។

ឈុនលី : មិនមែនលើកទត្រពាំងថ្មទេ?

ពួយ : ទេ ខ្ញុំមិនបានទៅទេ ។

វ៉ាត់ : ជំនាន់យាយនេះអត់ទៅទេបើអ៊ឹទៅជាមួយកូនគាត់ ។

ឈុនលី : អ៊ឹទៅជាមួយកូនគាត់?

វ៉ាត់ : ចាស! សៅរឿងកូនគាត់ ។ បើអត់ភ្លៀងគ្រាន់ បើមានភ្លៀងមិនបានដេកទេ បញ្ឈរភ្នែក វាស់ព្រឹក ។

ឈុនលី : អ៊ឹឈ្មោះអីអ៊ឹ?

ពួយ : ឈឹម ពួយ ។

ឈុនលី : ឈឹម ពួយ ។ អាយុប៉ុន្មានហើយ?

ពួយ : ៧៥ ហើយ ។

ឈុនលី : អ៊ឹអ្នកស្រុកហ្នឹងតាំងពីដើមមកដែរហ្អី?

ពួយ : ចាស!ខ្ញុំកើតនៅនេះ ។

ឈុនលី : ផ្ទះអ៊ឹនៅឯណា?

ពួយ : នេះផ្ទះតូច ។

ឈុនលី : ហើយអ៊ឹកាលនោះគេហៅកូនអ៊ឹឲ្យទៅធ្វើការនៅត្រពាំងថ្ម?

ពួយ ៖ ចា៎! ត្រពាំងថ្ម ។

ឈុនលី ៖ គាត់អាយុប៉ុន្មានកូបហ្នឹង ។

ពួយ ៖ អាយុទើបតែប៉ុន្មានដណ្តប់ ឆ្នាំដូត ។

ឈុនលី ៖ ឈ្មោះអីគេ?

ពួយ ៖ ឈ្មោះសៅ រឿង ។

ឈុនលី ៖ សៅ រឿង?

ពួយ ៖ ចាស! ឪឈ្មោះរី ងាប់ហើយតាំងពីសង្គម ។ កំព្រាខ្ញុំកំព្រាប្តីតាំងពីកូននៅកំពស់នេះ មួយ
ទើបតែបេះវា កូនតែបីប៉ុណ្ណេះឯង ។

ឈុនលី ៖ ហើយទៅដីកហ្នឹងអីដឹងរឿងនៅត្រពាំងថ្មទេ?

ពួយ ៖ ទេ ខ្ញុំមិនបានដឹងទេយូរហើយ វាភ្លេងហើយ ។

ឈុនលី ៖ ហើយកូនអីទៅហ្នឹងឆ្នាំណា ចាំទេ?

ពួយ ៖ ទេ វាភ្លេចអស់ហើយដូច៧៧

ឈុនលី ៖ ៧៧ហ្អស?

ពួយ ៖ ចាស!៧៧ហើយកូនខ្ញុំទៅ ។

ឈុនលី ៖ ទៅជាមួយអីដែរ?

ពួយ ៖ ចាស!

ឈុនលី ៖ ចឹងបានន័យថា...

ពួយ ៖ ជម្លៀសទៅភ្នំស្រះទៅនៅស្រះ ទៅនៅទឹងរន្ទះបាញ់គេជម្លៀសពីភូមិនេះទៅ ខ្វាត់ខ្វែង
ណាស់ ។ ទៅនៅស្រះម្តង ទៅនៅរន្ទះបាញ់ម្តង ។

ឈុនលី ៖ កូនប្តក៏យ៉ាងម៉េច?

ពួយ ៖ ខ្ញុំកូនទាំងអស់ដល់តែពេលពារឲ្យចូលភូមិ គេជម្លៀសចេញ ។

ឈុនលី ៖ ចុះកូនអីទៅត្រពាំងថ្មហ្នឹងឆ្នាំ៧៧?

ពួយ ៖ ចាស!

ឈុនលី ៖ ទៅហ្នឹងទៅជីកដំបូងប្តក៏មានគេទៅជីកមុនហើយនៅ?

ពួយ ៖ ពីដើមមិញទៅគេឲ្យស្ទូងដក ឈប់ស្ទូងដកគេឲ្យទៅមិញនោះ...

ឈុនលី ៖ ស្ពានរាប ត្រពាំងថ្ម?

ពួយ ៖ ត្រពាំងថ្ម ហើយអីណោះគេឲ្យលើកទំនប់ប្រឡាយសម្ព័ន្ធរួចបានឲ្យលើកអាងត្រពាំងថ្មវិញ ។

ឈុនលី ៖ ហ្នឹងកូនទេហ្អីមិនមែនអ៊ំទេ?

ពួយ ៖ កូន កូនខ្ញុំបង្កើត ។ ខ្ញុំនៅខាងណោះ ។

ឈុនលី ៖ តែកូនអ៊ំមួយហ្នឹងទេហ្អី?

ពួយ ៖ ចាស!

ឈុនលី ៖ កូនទាំងអស់មានប៉ុន្មានចឹង?

ពួយ ៖ កូនទាំងអស់មានបួន ងាប់អស់ពីរបីហើយ ។

ឈុនលី ៖ គាត់កូនទីប៉ុន្មាន?

ពួយ ៖ កូនទីមួយ ។

ឈុនលី ៖ សៅ រឿងហ្នឹងហ្អី?

ពួយ ៖ ចាស!សៅ រឿងកូនទីមួយឆ្នាំជូតឡើងធំស្លៀកទៅណាសកូន ។

ឈុនលី ៖ កាលនោះគេឲ្យជីកប៉ុន្មានម៉ែត្រ?

ពួយ ៖ បីម៉ែត្រគីប ។

ឈុនលី ៖ បីម៉ែត្រ?

ពួយ ៖ ចាស!បីម៉ែត្រគីប ។

ឈុនលី ៖ ម៉េចបានអ៊ំដឹង?

ពួយ ៖ ចុះខ្ញុំធ្លាប់លើកដែរនោះ!

ឈុនលី ៖ ចុះក្រែងគាត់អត់លើកត្រពាំងថ្មទេ?

ពួយ ៖ ទេខ្ញុំមិនបានលើកទេ ទៅតែកូនខ្ញុំ ។

ឈុនលី ៖ ចឹងពេលដែលកូនទៅអ៊ំអត់ដឹងរឿងអីទាក់ទងជាមួយកូនទេ?

ពួយ ៖ ទាក់ទងមិនបានទៅឆ្ងាយណាស់ ។

ឈុនលី ៖ ទៅយូរទេបានដឹងថាស្លាប់?

ពួយ ៖ ទៅយូរ ។

ឈុនលី ៖ ទៅធ្វើការនៅត្រពាំងថ្មហ្នឹងយូរ?

ពួយ ៖ ចាស!យូរ ។

ឈុនលី ៖ ចុះកាលនោះអ៊ំដឹងទេ ដឹងថាកូនគាត់ស្លាប់ទេ?

វ៉ាត់ : ខ្ញុំទៅក្រោយវ៉ា ។

ពូយ : មីនាងទៅក្រោយ វ៉ាទៅមុនបេ្តជ្ញាមុន ។

ឈុនលី : ៧/៧ហ្អី?

ពូយ : ចាស!៧/៧ ។

ឈុនលី : អ៊ឹចាំច្បាស់ម៉ែងហ្អី៧/៧?

ពូយ : ចាស!៧/៧ហើយ ។

ឈុនលី : ទៅមុនហ្នឹងដឹកដំបូងគេហើយចឹង?

ពូយ : ចាស!

ឈុនលី : អ៊ឹទៅហ្នឹងទៅតាមក្រោយគេ?

វ៉ាត់ : ទៅតាមក្រោយគេ ។

ឈុនលី : ចឹងគេដឹកហើយខ្វះហើយហ្នឹង?

ពូយ : ហ៊ឹស!គេដឹកបានហើយបានពួកនេះទៅ ។

ឈុនលី : អ៊ឹដឹងទេថាអាងហ្នឹងប៉ុណ្ណា?

ពូយ : ទេ ខ្ញុំមិនដឹងទេ អាងត្រពាំងថ្មធំហ្នឹងឯង ធំណាស់កូន ទឹកឡើងមានក្រពើ ។

ឈុនលី : ពេលអ៊ឹទៅតាមក្រោយហ្នឹងកូនគាត់ស្លាប់ឬនៅ?

វ៉ាត់ : មិនទាន់ស្លាប់ទេ នៅ ។

ពូយ : ហើយពេលទៅត្រពាំងថ្មអ៊ឹជួបកូនគាត់ដែរអត់?

វ៉ាត់ : អត់បានជួបផង ។

ឈុនលី : តែគាត់ទៅដែរ?

វ៉ាត់ : ទៅ វ៉ាទៅមុនខ្ញុំទៅក្រោយ ។

ពូយ : គេដឹកមក ដូចថារួចអាងត្រពាំងថ្មហើយណាស គេដឹកទៅភ្នំលាភកូនខ្ញុំវ៉ាគ្រូនក្ដៅ ។

ឈុនលី : ភ្នំលាភ?

ពូយ : នៅភ្នំលាភនៅខាងកើត ។

ឈុនលី : ភ្នំលាភ ចុះអ៊ឹថាស្ពានរាប?

វ៉ាត់ : អាមួយភ្នំលាភ អាមួយស្ពានរាប

ពូយ : ដល់ឈឺមើលមិនជាហៅរកម៉ែ ពេទ្យនិយាយប្រាប់ណាសដែលមកណាស ។

ឈុនលី : និយាយពេលណាអ៊ឹ?

ពួយ : ដែលពេទ្យគេទៅព្យាបាលពេលគេមកភូមិស្រុកវិញក៏គេប្រាប់ ថាម៉ែអឺយមិនបាច់មើល មិត្តរឿងទេ មិត្តរឿងខូចហើយ ។ ហ៊ឺ!ខូចហើយម៉េចក៏អញមិនដឹង ។ ខូចហើយ គេយក ពីទំនប់ទៅ ក្តៅខ្លាំងគេដឹកទៅស្វាយ ។ ដឹកទៅស្វាយគេធ្វើខ្ទមមួយក្រោមម្ចប់ឈើដាក់គ្រែ ឲ្យដេកអង្ក្រងខាំគ្នាជិតភ្នែកអស់ កូនខ្ញុំវាយំណាស់ ។ ស្តាយកូនវាចិត្តល្អ ស្រែកថា ម៉ែអឺយ!ខ្ញុំក្តៅណាស់ ម៉ែអឺយ!ខ្ញុំស្រេកទឹក ។ មីរឿងវារផាខ្ញុំឲ្យភួយទៅមីរឿង ពេទ្យនោះ មកនិយាយប្រាប់ ។ ថ្នាំអាអាចម៍ទន្សាយខ្ចប់ផ្ញើរម្តាយ ពុម្តាយឈឺផ្ញើរមកម្តាយ ខ្ញុំស្រណោះកូនខ្ញុំណាស់ កំសត់ណាស់កូនខ្ញុំកើតមកធំបន្តិចទៅនៅស៊ីឈ្នួលគេចិញ្ចឹមម្តាយ ព្រោហម្តាយកូនតូច ។ ប្តីខ្ញុំផាប់ហ្នឹងពីសង្គមសម័យលន់ នល់ ។ ដែកគោលមុតមិនមាន ប្រាក់ចាក់ថ្នាំ គាត់ទៅហូបអន្លង់ទៅវាចុះក្អួត អាជាតិប្រេសហ្នឹង ។

ឈុនលី : ចុះអ៊ីដឹងថាកូនស្លាប់ហ្នឹងដោយសារពេទ្យប្រាប់ហ្អី?

ពួយ : ចាស!

ឈុនលី : ពេទ្យហ្នឹងជួយគាត់ដែរហ្អី?

ពួយ : ចាស!ជួយដែរគេចិត្តល្អប្រាប់ខ្ញុំ ។

ឈុនលី : ចឹងអ៊ីអត់មានខឹងពេទ្យហ្នឹងអីណាហ្អី?

ពួយ : ទេ ខ្ញុំមិនបានខឹងគេទេ ធ្វើម៉េច ។ គេមិនថាកូនឯងទេ គេថាកូនអង្គការ ។

ឈុនលី : ពេលគេហៅទៅហ្នឹងហ្អី?

ពួយ : ចាស ហៅទៅប្រជុំហ្នឹងគេថាពុកម៉ែកុំឲ្យគិតកូនពេកមិនមែនកូនពុកម៉ែទេ កូនអង្គការ គេថាចេះ ។

ឈុនលី : ចុះអ៊ីសព្វថ្ងៃនៅជាមួយអ្នកណាគេ?

ពួយ : ខ្ញុំនៅម្នាក់ឯង ។

ឈុនលី : ចុះកូនៗទៅណាអស់ហើយ?

ពួយ : កូនមានអីវាក្រដែរ ចិញ្ចឹមចៅកំព្រា ប្តីរត់ចោលទៀត ។

ឈុនលី : អ៊ីនៅចិញ្ចឹមចៅទៀត?

ពួយ : វាហ្នឹងឯងកូនវា ចៅខ្ញុំ ។

ឈុនលី : អ៊ីឥឡូវហ្នឹងអាយុ៧០ ?

ពួយ : ខ្ញុំ៧៥ ៧៦ហើយ ។

ឈុនលី : ហើយឥឡូវនៅតែនឹកឃើញកូន?

ពួយ ៖ នៅតែនឹកឃើញកូន ។

ឈុនលី ៖ ដល់ពេលនឹកឃើញចឹងអ៊ីខឹងទេរបបហ្នឹង?

ពួយ ៖ ចាស នឹកខឹងហើយកូន ។

ឈុនលី ៖ ស្អប់របបហ្នឹងទេ?

ពួយ ៖ ស្អប់ ខ្ញុំមិនស្រលាញ់ទេ ។

ឈុនលី ៖ ចុះអ៊ីរាល់ថ្ងៃដឹងរឿងគេកាត់ទោសខ្មែរក្រហមដែរ?

ពួយ ៖ ចាស មិនដឹងអីទេកូន ។

ឈុនលី ៖ អត់ដឹងទេ?

ពួយ ៖ ចាស មិនដឹងអីទេ ។

ឈុនលី ៖ ចុះកាលជំនាន់នោះដែលពុកឈ្មោះមេដឹកនាំខ្មែរក្រហមទេ?

ពួយ ៖ ពូខ្លះហ្នឹងឯង ។

ឈុនលី ៖ ឈ្មោះអីខ្លះទៅ?

ពួយ ៖ មានឈ្មោះ តាម៉ុក អីគេនោះណាស ហួស!ច្រើនណាស់អង្គការអ្នកនេះអ្នកនោះ តាម៉ោង តារ៉ាល់ តាអីណាទេមិនស្គាល់ទេ នាងនួននាងអីនោះឃើញគេឡើងវិញហើយ ខ្លាច តែហ៊ានហៅហើយបាត់មួយហើយធ្វើខុសបន្តិចក៏មិនបាន ស្លូតស្រូវមិនបានស្អាតក៏ មិនសុខចិត្តដេញឲ្យទៅធ្វើទៀត ។ តាមដានយូរទៅចង់យកទៅវ៉ៃចោលទៀត ។

ឈុនលី ៖ ឥឡូវនេះគេមានតុលាការកាត់ទោសខ្មែរក្រហមហើយអ៊ី ។

ពួយ ៖ ចាស!ខ្ញុំមិនដឹងដែរណាសកូន ។

ឈុនលី ៖ គេមានហើយ ហើយគេកាត់ទោសមេធំៗមានអៀង សារី អៀង ធិរិទ្ធប្រពន្ធគាត់ នួន ជា ខៀវ សំផន ហើយមួយទៀត តាឌុច មេគុកទួលស្លែងណាសអ៊ី ។

ពួយ ៖ ចាស!

ឈុនលី ៖ ធ្លាប់ពុទេ?

ពួយ ៖ ធ្លាប់ពុដែរគុកទួលស្លែង ។

ឈុនលី ៖ ហើយគេកាត់ទោសឌុចហ្នឹងតាំងពីឆ្នាំ២០០៩៦ណោះ ឥឡូវហ្នឹងរឿងក្តីគាត់ជិតចប់ ហើយ ហើយខែ៦នេះគេជិតចាប់ផ្តើមបើកសវនាការបួននាក់ទៀតហ្នឹងដែលមាន នួន ជា អៀង សារីអីហ្នឹង ហើយខែ៦នេះគេចាប់ផ្តើមបើកហើយ ។

ពួយ ៖ ចាំ!

ឈុនលី : ហើយអ៊ីសប្បាយចិត្តទេពេលមានតុលាការអ៊ីចឹង?

ពួយ : ចាស!ខ្ញុំសប្បាយចិត្តណាស់លោកគ្រូ ។

ឈុនលី : ហើយពួកគាត់ចាស់ៗអស់ហើយ ចិត ប៉ែតហើយ ។

ពួយ : ចាស!ណុងឯងគាត់យូរដែរហើយនោះ ។

ឈុនលី : ហើយគាត់ចាស់ចឹងអ៊ីគិតថាគួរតែកាត់ទោសគាត់ដែរទេ? អាណិតគាត់ដែរអត់មើលទៅឃើញគាត់ចាស់ៗចឹង?

ពួយ : ទេខ្ញុំមិនដឹងឆ្លើយថាយ៉ាងម៉េចទេ!

ឈុនលី : ចំពោះយោបល់អ៊ីដូចអ៊ីបាត់បង់កូនក្នុងសម័យនោះ?

ពួយ : ចាស!

ឈុនលី : អ៊ីនៅខឹងទេ?

ពួយ : ខ្ញុំនៅតែខឹង?

ឈុនលី : នៅខឹង ពួកខ្មែរក្រហមហ្នឹង?

ពួយ : ចាស! វាស្រណោះកូនដែលស្រលាញ់ម្ដាយ ម្ដាយក៏ស្រលាញ់កូនកំព្រាឪពុក ។

ឈុនលី : ចុះអ៊ីខស្សានិយាយរឿងហ្នឹងប្រាប់កូនចៅដែរ?

ពួយ : ខ្ញុំប្រាប់ខ្លះដែរ ។

ឈុនលី : ហើយគេជឿទេ?

ពួយ : ជឿហ្នឹងហើយ ។

ឈុនលី : ក្មេងៗជឿដែរ?

ពួយ : ចាស ជឿ ។ ស្ដាយណាស់កូន សុខចិត្តងាប់ឯងឲ្យតែបានកូនស៊ីដល់តែកូនធំឡើងយកទៅមិនមកវិញអី ងាប់ ។

ឈុនលី : ឥឡូវគេកំពុងកាត់ទោសខ្មែរក្រហមណាសអ៊ីមាន នួន ជា អៀង សារី ខៀវ សំផន អៀង ធិរិទ្ធប្រពន្ធរបស់ អៀង សារី ហើយមាន តាឌុច មានអីហ្នឹងណាសអ៊ី ។

វ៉ាត់ : តាឌុច?

ឈុនលី : តាឌុច មេគុកទួលស្លែង ទួលស្លែងនៅភ្នំពេញ គុកធំជាងគេ...

វ៉ាត់ : អានោះចងទាល់តែឃើញផ្ទឹងជាប់នឹងចំណង ។

ឈុនលី : គេកាត់ទោសគាត់ជិតចប់ហើយ ។

ពួយ : គេលេងខយើងមើលដែរតើ!

ឈុនលី ៖ លេងនៅឯណាវិញអ៊ី?

ពួយ ៖ នៅនឹងវត្ត យូរហើយ ។

ឈុនលី ៖ បានមកពីណាកុនហ្នឹង

រ៉ាត់ ៖ គេថតពីណុងមក ។

ឈុនលី ៖ អ្នកណាយកមកបញ្ចាំង ខាងណាវិញ?

ពួយ ៖ ទេ ចាំមិនបានតាំងពីសន្តិភាពរួចមកម្លេះ ។

ឈុនលី ៖ តាំងពីជំនាន់មុនដែរហ្អី?

ពួយ ៖ ចាស!យូរហើយ ។

រ៉ាត់ ៖ តាំងពីវៀតណាមចូលមកដល់ ។ គេថាអន្ទង់ៗអីស្រះគេសម្លាប់មនុស្ស ។

ឈុនលី ៖ ស្រះឯណាស្រះគេសម្លាប់មនុស្ស?

ពួយ ៖ មិនដឹងនៅឯណាទេ ។

រ៉ាត់ ៖ ឃើញតែក្បាលល្វេកល្វោក ។

ឈុនលី ៖ ចុះអ៊ីមានដែលទៅមើលអាងត្រពាំងថ្មទៀតទេ?

រ៉ាត់ ៖ អត់ដែលបានទៅ ។

ឈុនលី ៖ អត់ចង់ទៅប៉ុយ៉ាងម៉េច?

រ៉ាត់ ៖ ថាមិនចង់ទៅដែរ តែបើគេឲ្យទៅក៏ទៅ ។

ឈុនលី ៖ ឆ្ងាយពេកប៉ុយ៉ាងម៉េចបានមិនដែលទៅ?

ពួយ ៖ មិនចង់ទៅ សង្វេកកូន ។

ឈុនលី ៖ ចុះអ៊ីស្រីដែលធ្លាប់ធ្វើការនៅនោះ?

រ៉ាត់ ៖ ទេបើយើងជាស្រួលចេះតែចង់ទៅតែបើមិនស្រួលមិនចង់ទៅ បើកំលាំងខ្សោយទៅឯណា តែកំលាំងយ៉ាប់ហើយទៅមិនរួចទេ ។

ឈុនលី ៖ អ៊ីខស្ប្រាហ៍និយាយរឿងប្រាប់កូនក្មេងទេដូចអ៊ីពិបាកអីចឹង?

រ៉ាត់ ៖ ប្រាប់ថាពិបាកចឹង ។

ឈុនលី ៖ ក្មេងៗជឿដែរទេ?

រ៉ាត់ ៖ វាជឿ វាថា មើលគាត់តស៊ូបានមកដល់សម័យនេះបើខ្ញុំបែបស្លាប់បាត់ហើយ ។

ឈុនលី ៖ ចុះដល់ពេលក្មេងៗជឿចឹងអ៊ីសប្បាយចិត្តទេ?

រ៉ាត់ ៖ សប្បាយ ។

ឈុនលី : ធូរចិត្តដែរ?

វ៉ាត់ : ចាស!ធូរ ៗ

ឈុនលី : ចុះបើគេអត់ជឿ?

វ៉ាត់ : ពួកវាជឿ យ៉ាប់ប៉ុណ្ណាពិបាកប៉ុណ្ណាវាជឿសម័យនេះស្រួលហើយ ។

ឈុនលី : ចាស!អ៊ីចឹងខ្ញុំអគុណច្រើនហើយអ៊ំ!

វ៉ាត់ : ចាស!

«ចប់»